ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ២០ ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម - ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I . ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

០៨-៦-១៩៩៥ – អនុក្រឹត្យលេខ ៤៦ អនក្រ. បក ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈចាំបាច់ និង បន្ទាន់របស់ក្រសួងការពារជាតិ ៨១៥
០៨-៦-១៩៩៥ – អនុក្រឹត្យលេខ ៦៨ អនក្រ. តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨១៦

២-សេចក្តីសំរេច

០៥-៦-១៩៩៥ – សេចក្តីសំរេចលេខ ៤១ សសរ ស្តីពីការផ្ទេរសិទ្ធិ ៨១៧
០៦-៦-១៩៩៥ – សេចក្តីសំរេចលេខ ៤២ សសរ ស្តីពីការបង្កើតគណៈកម្មការ សំរាប់ ចុះស្រាវជ្រាវ លើករណីផ្លូវលេខ ១០៣ ពន្លៃឆ្នុកទ្រូ ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ៨១៨

II-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

០៥-៦-១៩៩៥ – ប្រកាសលេខ ១៦៧ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន ៨២០
០៦-៦-១៩៩៥ – ប្រកាសលេខ ១៧០ ប្រក. សហវ. ព. ជ ស្តីពីពន្ធលើប្រាក់បៀវត្ស ៨២២
០៨-៦-១៩៩៥ – ប្រកាសលេខ ១៧៨ ប្រក. សហវថ ស្តីអំពីការបង្វែរឥណទាន ៨៤៥

២-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

០២-៦-១៩៩៤ – ប្រកាសលេខ ៤០៨ ផក.ប្រក អនុញ្ញាតអោយលោក ម៉ែន ម៉េង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣១ សេះ ៨៤៦

០២-៦-១៩៩៥ – ប្រកាសលេខ ៤០៩ ផក.ប្រក អនុញ្ញាតអោយលោក ម៉ែន ម៉េង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៣១ សេះ ៨៤៧

០៣-៦-១៩៩៥ – ប្រកាសលេខ ៤១៥ ផក.ប្រក អនុញ្ញាតអោយលោក ឈាន ណេង ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ ៨៤៧

០៣-៦-១៩៩៥ – ប្រកាសលេខ ៤១៦ ផក.ប្រក អនុញ្ញាតអោយលោក ហម ចាន់ឡាយ ជនជាតិខ្មែរ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ ៨៤៨

៣-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

០៥-៦-១៩៩៥ – ប្រកាសលេខ ១១៤ /៩៥ ពម.ប្រក អនុញ្ញាតអោយ លោក តួច សាខន បើកអាជីវកម្មរោងពុម្ពឈ្មោះ «ដំបងដែក» ៨៤៩

០៥-៦-១៩៩៥ – ប្រកាសលេខ ១១៥ /៩៥ ពម.ប្រក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង ៨៥០

០៧-៦-១៩៩៥ – ប្រកាសលេខ ១១៥ /៩៥ ពម.ប្រក ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ ៨៥១

០៧-៦-១៩៩៥ – ប្រកាសលេខ ១១៧ /៩៥ ពម.ប្រក ស្ដីពីការអនុញ្ញាតអោយកាសែតឈ្មោះ (LE QUOTIDIEN DU CAMBODGE)

	ចេញផ្សាយជាភាសាខ្មែរ–បារាំង ដោយមានលោក ម៉ែន សាម៉ាន ជាថាងហ្វាងការផ្សាយ	៨៥២
០៨–៦–១៩៩៥	– ប្រកាសលេខ ១១៨ /៩៥ ពម.ប្រក អនុញ្ញាតអោយ លោក ស៊ីរីគិចសុវណ្ណ «SIRI KIJSUWAN» សញ្ជាតិថៃ បើក ការិយាល័យផ្សព្វផ្សាយពាណិជ្ជកម្ម PRAKIT / FCB	៨៥៣

៤-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ប្រកាស

០៣–៦–១៩៩៥	– ប្រកាសលេខ ១១២ ប្រក.វវស.បុ ស្ដីពីការបង្កើតគណៈកម្មការ និង អនុគណៈកម្មការរៀបចំកម្មវិសិក្សាសិល្បៈជាមួយក្រសួងអប់រំ	៨៥៤
០៨–៦–១៩៩៥	– ប្រកាសលេខ ១១៤ ប្រក.វវស.បុ ស្ដីពីការលុបឈ្មោះមន្ត្រីរាជការ	៨៥៦

៥-ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

០២–៦–១៩៩៥	– ប្រកាសលេខ ៦៤៥ អយក.ប្រក ស្ដីពីការកំណត់មណ្ឌលប្រឡង សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២	៨៥៧
០៦–៦–១៩៩៥	– ប្រកាសលេខ ៦៥៣ អយក.ប្រក ស្ដីពីការបើកសាលារៀនកុមារ ពិការភ្នែក	៨៦១
០៦–៦–១៩៩៥	– ប្រកាសលេខ ៦៥៤ អយក.ប្រក ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិ ទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១	៨៦២

I .ទីស្តីការគណៈរដ្ឋមន្ត្រី

១-អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤៦ អនក្រ.បក

អំពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈ
ចាំបាច់ និង បន្ទាន់ របស់ក្រសួងការពារជាតិ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងអនុក្រឹត្យលេខ ៤១ អនក្របក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៥ ស្តីពីការបញ្ជាចំណាយឥតគ្រោងទុក ដែលមានលក្ខណៈចាំបាច់ និងបន្ទាន់របស់ក្រសួង ការពារជាតិ
- យោងតាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

មាត្រា ១ : កំណត់អោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោះស្រាយថវិកាសំរាប់ការចំណាយ ដែលចាត់ទុកជាតម្រូវការប្រញាប់របស់រាជរដ្ឋាភិបាល ដូចខាងក្រោម :

១-ការចំណាយសំរាប់សាងសង់បន្ទាយសុវត្ថិភាព អោយកំលាំងការពារនាយករដ្ឋមន្ត្រីទី ១ មានទឹកប្រាក់ចំនួន ៤៨៧.០០០ ដុល្លារអាមេរិក ស្មើនឹង ១.១២០.១០០.០០០៖០០ (មួយពាន់មួយរយម្ភៃលានមួយរយពាន់រៀលគត់ គិតតាមអត្រាថ្ងៃទី ៣១-៥-៩៥ ២.៣០០៖០០ ក្នុងមួយដុល្លារអាមេរិក ។

២-ការចំណាយមានចំនួនទឹកប្រាក់ ៤២៤.៦៣៣,៥០ ដុល្លារអាមេរិក (បួនរយម្ភៃបួនពាន់ប្រាំមួយរយសាមសិបបីដុល្លារអាមេរិក និង ហាសិបសេន) សំរាប់ទូទាត់ថ្លៃទិញយន្តហោះ Y-12 ចំនួន ២ គ្រឿង ។

មាត្រា ២ : ការកំណត់ក្នុងការដោះស្រាយថវិកា ដែលបានចែងក្នុងចំណុចទី ៥ មាត្រា ១ នៃអនុក្រឹត្យលេខ ៤១ អនក្របក ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៩៥ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង អាជ្ញាធរពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះអោយបានសំរេច ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៦៨ អនក្រ.បក

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : តែងតាំងលោកស្រី **ម៉ែន ឆ្ងីស៊ន** ជានាយកពិធីការសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី ១ នៃរាជរដ្ឋាភិបាលកម្ពុជា ដែលមានឋានៈស្មើនឹង នាយកខុទ្ទកាល័យសម្តេចក្រុមព្រះ ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនដែលមានឈ្មោះក្នុង មាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ។

នាយករដ្ឋមន្ត្រីទី ១	**នាយករដ្ឋមន្ត្រីទី ២**
ព្រះហស្តលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៤១ សសរ

ស្តីពីការផ្ទេរសិទ្ធិ

* * *

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

– បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

– យោងតាមការងារចាំបាច់

សំរេច

ប្រការ ១ : ត្រូវបានផ្ទេរភារកិច្ចជូនឯកឧត្តម **ឈា ចាំង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជារដ្ឋមន្ត្រីស្តីទីក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ក្នុងឱកាសដែលឯកឧត្តម **ស៊ុយ សែម** អញ្ជើញទៅបំពេញបេសកកម្មនៅឯបរទេសចាប់ពីថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៥ រហូតដល់ពេលឯកឧត្តមអញ្ជើញត្រឡប់មកវិញ ។

ប្រការ ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម **ឈា ចាំង** ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ២
ហត្ថលេខា និង ត្រា
ហ៊ុន សែន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៤២ សសរ

ការបង្កើតគណៈកម្មការសិរាប់ចុះស្រាវជ្រាវលើករណីផ្លូវ លេខ ១០៣ ពន្ធ ឆ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង

* * *

រាជរដ្ឋាភិបាល

– បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ

តែងតាំងរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- យោងតាមសំណូមពរការងារចាំបាច់

សម្រេច

ប្រការ ១ : បង្កើតគណៈកម្មការមួយមានឈ្មោះថា «គណៈកម្មការស្រាវជ្រាវករណីលើផ្លូវលេខ ១០៣ ពាន្ទេ ធ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង» ហៅកាត់ថា «គណៈកម្មការផ្លូវធ្នុកទ្រូ» ដែលមានសមាសភាពដូចតទៅ ÷

១-តំណាង ក្រសួងមហាផ្ទៃ	ប្រធាន
២-តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
៣-តំណាង ក្រសួងហិរញ្ញវត្ថុ	សមាជិក
៤-តំណាង សាលាខេត្តកំពង់ឆ្នាំង	សមាជិក
៥-តំណាងការិយាល័យទទួលពាក្យបណ្តឹង នៃទីស្តីការគណៈរដ្ឋមន្ត្រី	លេខាធិការ

ប្រការ ២ : គណៈកម្មការផ្លូវធ្នុកទ្រូ មានភារកិច្ចដូចតទៅ :

- ស្រាវជ្រាវអោយបានច្បាស់លាស់លើករណីវិនិយោគជួសជុលផ្លូវ ដោយមានការហូតពន្ធនៅលើផ្លូវលេខ ១០៣ ពាន្ទេ ធ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ។
- សរុបរបាយការណ៍ និងលើវិធានការដោះស្រាយ ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : គណៈកម្មការផ្លូវធ្នុកទ្រូ មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ដើម្បីចូលរួមបំពេញការងារតាមការជាក់ស្តែង ។

ប្រការ ៤ : សមាជិកទាំងអស់ នៃគណៈកម្មការផ្លូវធ្នុកទ្រូ ត្រូវចូលរួមប្រជុំ និងធ្វើការងារតាមសេចក្តីអញ្ជើញ និងការណែនាំរបស់ប្រធាន ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាលាខេត្តកំពង់ឆ្នាំង និង សាមីខ្លួន ត្រូវសហការអនុវត្តសេចក្តីសរេចនេះ អោយមាន

ប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខា និង ត្រា	ហត្ថលេខា និង ត្រា
នរោត្តម រណឫទ្ធិ	ហ៊ុន សែន

* * *

II. ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៦៧ ប្រក.សហវ.៩

ស្តីអំពីការបង្វែរឥណទាន

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងការពារជាតិ លេខ ០៩២.៩៥ នថក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ១៩៩៥

សំរេច

ប្រការ ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិការបស់ក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោម នេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទាន ថ្មី
						កើន	ថយ	
១១	០១	១២	០២	ការបង្វែរពីជំពូក ១១ សំភារៈមន្ទីរពិសោធន៍ និង សំភារៈ បច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ	១៣៨.០០០	–	១៣៨.០០០ ១៣៨.០០០	០.
១១	០១	១២	០៣	ផលប្រយោជន៍ជំពូក ១១ សិក្ខាសាលា និង កិច្ចប្រជុំ	០	១៣៨.០០០ ១៣៨.០០០	–	១៣៨.០០០

ប្រការ ២ : ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាស នេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ឆាយ ថន

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាស លេខ : ១៧០ ប្រក.សហវ.៣៥

ស្តីពីពន្ធលើប្រាក់បៀវត្ស

* * *

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល .
- បានឃើញច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ នស ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ សំខាន់មាត្រា ៩ ដល់មាត្រា២៤
- បានឃើញច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ហើយដែលបានបង្កើតនិតិវិធីនៃ ការត្រួតពិនិត្យ និង ការកំណត់ពន្ធឡើងវិញព្រមទាំងការពិន័យ ដែលត្រូវអនុវត្តជាពិសេសមាត្រា ២៤និង មាត្រា ៥៧ ដល់ មាត្រា ៦០
- បានឃើញការចាំបាច់ក្នុងការធ្វើអោយបានល្អប្រសើរនូវប្រព័ន្ធសារពើពន្ធ ដើម្បីបង្កើនចំណូលថវិការដ្ឋ ។

សំរេច

ប្រការ ១ : បទបញ្ញត្តិទាំងឡាយខាងក្រោម ដែលចែងអំពីនិយមន័យនៃប្រាក់ចំណូលដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ការកំណត់មូលដ្ឋានគិតពន្ធនេះ និង បែបបទកំណត់ពន្ធដែលត្រូវអនុវត្ត គឺជាគោលការណ៍ជាមូលដ្ឋានសំរាប់អនុវត្តការប្រមូលពន្ធលើប្រាក់បៀវត្ស ។

ប្រការ ២ : អង្គការពន្ធដែលទទួលបន្ទុកកំណត់មូលដ្ឋានគិតពន្ធ ប្រមូលពន្ធ និង ទទួលបន្ទុកការងារត្រួតពិនិត្យពន្ធលើប្រាក់បៀវត្ស និង សហគ្រាសដែលទទួលបន្ទុកកាត់ទុកប្រាក់ពន្ធ និង បង់ប្រាក់ពន្ធដែលបានកាត់ទុកនេះជូនរដ្ឋ ត្រូវផ្អែកដូចគ្នាលើគោលការណ៍ជាមូលដ្ឋាននេះ សំរាប់អនុវត្តភារកិច្ច និង កាតព្វកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៣ : បទបញ្ញត្តិទាំងឡាយមានដូចខាងក្រោមនេះ និង ចែកជា ៦ ជំពូក :

- ជំពូកទី ១ – ដែនអនុវត្តនៃពន្ធ
- ជំពូកទី ២. – មូលដ្ឋានកំណត់ពន្ធ
- ជំពូកទី ៣. – ដែនដីនៃពន្ធ
- ជំពូកទី ៤. – ការគណនាប្រាក់ពន្ធ
- ជំពូកទី ៥. – ហេតុបណ្តាលអោយជាប់ពន្ធ
- ជំពូកទី ៦. – កាតព្វកិច្ចរបស់និយោជក

ជំពូកទី ១

ដែនអនុវត្តនៃពន្ធ

ផ្នែកទី ១ . បុគ្គលជាប់ពន្ធ

ត្រូវជាប់ពន្ធលើប្រាក់បៀវត្សទៅតាមមាត្រា ១០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ គ្រប់បុគ្គលដែលមានលក្ខណៈជាអ្នកបំរើការងារនៅក្នុងសហគ្រាសសាធារណៈ ឬ ឯកជន ។ គឺជាបុគ្គលដែលបំពេញសកម្មភាពវិជ្ជាជីវៈរបស់ខ្លួនក្នុងក្របខ័ណ្ឌ នៃកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់មាត់ ។ ក្នុងការអនុវត្តន៍កិច្ចសន្យានេះបុគ្គលនោះ និង ត្រូវស្ថិតនៅ ក្រោមនីវាទរបស់បុគ្គលម្នាក់ទៀតជានិយោជក ដោយទទួលលាភការដែលជាទូទៅហៅ ថាប្រាក់បៀវត្ស។

ប្រៀបធៀបទៅនឹងវិជ្ជាជីវៈ និង សកម្មភាពឯករាជ្យនានា សកម្មភាពបំរើការងារយកប្រាក់បៀវត្ស ត្រូវបានចង្អុលបង្ហាញដោយស្ថានភាពស្ថិតក្រោមចំណុះនិយោជក និង ក្នុងស្ថានភាព នេះហើយដែលបុគ្គលនោះបំពេញសកម្មភាពរបស់ខ្លួន ។

ដែនអនុវត្តក្នុងមាត្រានៃច្បាប់ ត្រូវបានកំណត់ដោយមានកំរិត ព្រោះថាដែនអនុវត្ត នេះទាក់ទងចំពោះអ្នកបំរើការងារក្នុងសហគ្រាសសាធារណៈ និង ឯកជនតែប៉ុណ្ណោះ។

១-អ្នកបំរើការងារសហគ្រាសសាធារណៈ

ត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ប្រាក់ចំណូលដែលបានទទួលដោយអ្នកបំរើការងារក្នុងក្របខ័ណ្ឌនៃសហគ្រាសសាធារណៈ ពោលគឺ សហគ្រាសដែលមានមូលធនទាំងស្រុងជាកម្មសិទ្ធិ របស់រដ្ឋ របស់សមូហភាពសាធារណៈ ឬ ផ្នែករបស់ខ្លួន ។

លក្ខខ័ណ្ឌអាជីវកម្មរបស់សហគ្រាសសាធារណៈពុំមានឥទ្ធិពលទៅលើលក្ខណៈជាប់ពន្ធ ឬ មិនត្រូវជាប់ពន្ធនៃលាភការដែលសហគ្រាសសាធារណៈ បើកអោយអ្នកបំរើការងាររបស់ខ្លួននោះទេ ។

ដូចនេះត្រូវជាប់ពន្ធលើប្រាក់បៀវត្សនូវរាល់ប្រាក់ចំណូល ដែលបានទទួលពីការបំរើការងារក្នុងក្របខ័ណ្ឌនៃសហគ្រាសសាធារណៈ កាលបើសហគ្រាសនេះត្រូវបានគ្រប់គ្រងដោយ ផ្ទាល់ពីរដ្ឋ ពីសមូហភាពសាធារណៈ ឬ ផ្នែករបស់ខ្លួន ។

ក៏ដូចគ្នាដែរកាលបើជាសហគ្រាសដែលបានទទួលសម្បទានក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាសម្បទាន ។

២-អ្នកបំរើការងារសហគ្រាសឯកជន

ប្រាក់បៀវត្សដែលបានបើកអោយដោយសហគ្រាសឯកជន ត្រូវជាប់ពន្ធលើប្រាក់បៀវត្សទោះបីសហគ្រាសនោះ ជាសហគ្រាសឯកត្តជន ឬ ក៏ធ្វើអាជីវកម្មក្រោមរូបភាពជាក្រុមហ៊ុនក្តី ។ ថ្វីបើក្នុងកាលៈទេសៈនេះមិនទាន់មានច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ស្តីពីក្រុមហ៊ុនក៏ដោយ ក៏ពុំមានការលំបាកខ្លាំងក្នុងការវាយតំលៃអង្គភាពសេដ្ឋកិច្ចណាមួយមែន ឬ ពុំមែនជាសហគ្រាស នៃផ្នែកឯកជននោះឡើយ ដោយហេតុថា ក្នុងការវាយតំលៃ គឺ ចាំបាច់ត្រូវយោងទៅរកស្ថានភាពនៃអំពើរបស់អង្គភាពនោះ ។

៣-អ្នកបំរើការងារសហគ្រាសចំរុះ

តាមសមានកម្ម អ្នកបំរើការងារសហគ្រាសដែលមានមូលធនជាមូលនិធិសាធារណៈផង និង ជាមូលនិធិឯកជនផង ត្រូវជាប់ពន្ធដូចគ្នានូវពន្ធលើប្រាក់បៀវត្ស ។

ផ្នែកទី ២ . បុគ្គលដែលត្រូវបានលើកលែងពន្ធ

មាត្រា ១០ នៃច្បាប់បានកំណត់យ៉ាងច្បាស់ នូវបុគ្គលដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស និង លក្ខណៈវិនិច្ឆ័យសំខាន់ដែលត្រូវជាប់ពន្ធ គឺ ត្រូវជាបុគ្គលិកនៃសហគ្រាស ។

ផ្ទុយទៅវិញគ្រប់បុគ្គល ដែលជាអ្នកបំរើការងារ នៃនិយោជកដែលពុំមានលក្ខណៈជា សហគ្រាសពុំត្រូវជាប់ពន្ធឡើយ ។ ពន្ធលើប្រាក់បៀវត្សត្រូវបានលើកលែងចំពោះ :

- សមាជិក នៃបេសកកម្មការទូត និង អង្គការអន្តរជាតិដែលបានតាំងនៅព្រះរាជាណាចក្រកម្ពុជា
- ភ្នាក់ងារការទូត បុគ្គលិករដ្ឋបាល និង បច្ចេកទេសនៃបេសកកម្មការទូត
- សមាជិកនៃបុគ្គលិកផ្នែកបេសកកម្មការទូត
- សមាជិកនៃអង្គការមិនមែនរដ្ឋាភិបាល
- អ្នកជំនាញការធ្វើការងារដោយផ្ទាល់ ក្នុងក្របខ័ណ្ឌ នៃជំនួយបច្ចេកទេសពហុភាគី ឬ ទ្វេភាគី
- អ្នកបំរើការងារនៃគ្រប់សមាគម
- សមាជិកសភា និង អ្នកធ្វើការក្នុងក្រសួងនានា
- មន្ត្រីរដ្ឋបាលស៊ីវិល និង បុគ្គលិកយោធា
- និយោជិក និង អ្នកបំរើឯកជន

កំណត់សំគាល់ :

មាត្រា ១០ នៃច្បាប់បានរៀបរាប់យ៉ាងច្បាស់ និង បញ្ចូលក្នុងដែនអនុវត្តនៃពន្ធ លើប្រាក់បៀវត្សនូវប្រាក់ចំណូលដែលបានទទួលពីការបំពេញសកម្មភាពនៅក្នុង សហគ្រាសសាធារណៈ ឬ ឯកជនតែម៉្យាងប៉ុណ្ណោះ ។

ដោយហេតុនេះគ្រប់បុគ្គល ដែលបានទទួលអត្ថប្រយោជន៍ ពីសោធននិវត្តន៍ក្រោយ ពីការបំពេញការងារនៅក្នុងសហគ្រាសទាំងនេះ ត្រូវបានលើកលែងពន្ធលើប្រាក់បៀវត្ស ចំពោះប្រាក់សោធននិវត្តន៍នេះ ។

ជំពូកទី ២

មូលដ្ឋានកំណត់ពន្ធ

មូលដ្ឋានកំណត់ពន្ធលើប្រាក់បៀវត្ស គឺ រួមមានប្រាក់ចំណូលទាំងអស់ ប្រាក់បៀវត្សជាមូលដ្ឋានប្រាក់បំណាច់ បុព្វលាភ ប្រាក់អោយថែម និង អត្ថប្រយោជន៍ជាវត្ថុដែលបានមកពីការបំពេញសកម្មភាពនៅក្នុងសហគ្រាសសាធារណៈ ឬ ឯកជន។

ផ្នែកទី ១ . គោលការណ៍ទូទៅ

ចំនួនប្រាក់ទាំងអស់ដែលបានទទួល និង អត្ថប្រយោជន៍ជាវត្ថុដែលបាន ទទួលក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាការងាររវាងអ្នកបំរើការងារ ជាមួយសហគ្រាសត្រូវ ជាប់ពន្ធលើប្រាក់ បៀវត្ស ។

ចំណែកបន្ទាប់បន្សំនៃលាភការជាចំបងដែលជាប្រាក់បំណាច់ បុព្វលាភប្រាក់ ម៉ោង បន្ថែម ប្រាក់អោយថែមដែលបានផ្តល់អោយជាប្រាក់ ឬ អត្ថប្រយោជន៍ជា វត្ថុត្រូវជាប់ពន្ធដូចគ្នា នឹងប្រាក់បៀវត្សពិត ។ ដែរពីព្រោះប្រាក់ ឬ អត្ថប្រយោជន៍ជា វត្ថុទាំងនេះ ជាគតិយុត្តិ និង តាមច្បាប់ពន្ធមិនអាចបំបែកចេញបានឡើយ ។

ឧទាហរណ៍ :

- ការប្រគល់អោយប្រើប្រាស់ដោយឥតគិតថ្លៃ នូវទ្រព្យសំភារៈ ដូចជាលំនៅ សម្ភារីម រថយន្ត ។ល។
- ការផ្តល់ដោយឥតគិតថ្លៃ ឬ យកថ្លៃទាបជាងថ្លៃដើមពិតប្រាកដនូវទំនិញការ ផ្គត់ផ្គង់សេវា ការងារអចល ម្ហូបអាហារ អ្នកបំរើ ។ល។

ចំណែកបន្ទាប់បន្សំដែលចេញថ្លៃអោយទៅសេវាដែលបានផ្តល់នោះ គឺ ជា ប្រាក់បៀវត្សបន្ថែមដែលស្ថិតនៅក្នុងស្ថានភាពសារពើពន្ធដូចគ្នា និង លាភការ ដែលបានទទួលដែរនោះ បើចំណែកបន្ទាប់បន្សំទាំងនេះមានឈ្មោះថាជាអ្វីក៏ដោយ (ប្រាក់ បំណាច់ បុព្វលាភ ប្រាក់អោយថែម ប្រាក់គិរីក្រៅ ប្រាក់ម៉ោង បន្ថែម ប្រាក់វិភាជន៍ ម៉ៅផ្ដាច់សំរាប់សោហ៊ុយ ។ល។)

កំណត់សំគាល់ :

មូលដ្ឋានសំរាប់កំណត់ពន្ធលើប្រាក់បៀវត្ស គឺ ជាមូលដ្ឋានមុនគិតពន្ធ :

- ពន្ធដែលត្រូវគណនាលើចំនួនប្រាក់ទាំងអស់ និង អត្ថប្រយោជន៍ជាវត្ថុដែល បានផ្តល់អោយ គឺ ជាពន្ធដែលជាបន្ទុកជាប់ដោយឡែករបស់អ្នកបំរើការងារ ដែលជាអ្នកបានទទួល ប្រយោជន៍ពីប្រាក់ចំណូលជាប់ពន្ធ ។
- បច្ចេកទេសដោយឡែកនៃការកាត់ទុកប្រាក់ពន្ធមុនបើកប្រាក់បៀវត្សនោះមិន នាំអោយមានការកែប្រែគោលការណ៍ជាសារវ័ន្ត ស្តីពីការកំណត់មូលដ្ឋាន សំរាប់គិតពន្ធលើប្រាក់បៀវត្សនេះឡើយ ។
- ដូចនេះ និយោជកតាមច្បាប់ពន្ធ មិនត្រូវអនុញ្ញាតអោយទទួលបន្ទុកទាំងស្រុង

ឬ ដោយភាគខ្លះនូវពន្ធលើប្រាក់បៀវត្ស ដែលត្រូវបង់ដោយនិយោជិករបស់ខ្លួនឡើយ ។

- រាល់ការទទួលបន្ទុក នូវពន្ធលើប្រាក់បៀវត្សត្រូវចាត់ទុកថាជាប្រាក់បៀវត្សបន្ថែម ដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ។

ផ្នែកទី ២ . ចំណែកនៃលាភការជាប់ពន្ធ

(មាត្រា ១៥ នៃច្បាប់)

១-ប្រាក់បៀវត្សពិត

គឺជាលាភការដែលជាទូទៅមិនប្រែប្រួល ធានាចំពោះអ្នកបំរើការងារដោយកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ ឬ ផ្ទាល់ មាត់ ។ ប្រាក់បៀវត្សជាមូលដ្ឋានជាសំខាន់គឺបង្កឡើង ដោយលាភការដែលបាន ទទួលជាសាច់ប្រាក់ ។

២.ចំណែកបន្ទាប់បន្សំដែលបានទទួលជាសាច់ប្រាក់

ជាអាទិ គឺ ជាបុព្វលាភ ប្រាក់បំណាច់ ប្រាក់ម៉ោងបន្ថែម និង ចំណែកបន្ទាប់បន្សំផ្សេង ៗទៀតគ្រប់ប្រភេទ ។

២.១. បុព្វលាភ ប្រាក់ម៉ោងបន្ថែម :

ប្រាក់ទាំងនេះជានិច្ចកាល ត្រូវជាប់ពន្ធទោះបីអ្នកបានទទួលប្រយោជន៍មានលក្ខណៈយ៉ាងណាក្តីទោះបីបែបបទ និង កាលៈទេសៈនៃការផ្តល់ប្រាក់ទាំងនេះយ៉ាងណាក្តី ។

២.២. ប្រាក់បំណាច់ :

រាល់ចំនួនប្រាក់ដែលមានលក្ខណៈជាប្រាក់បំណាច់ត្រូវជាប់ពន្ធកាលបើចំនួនប្រាក់នេះមានលក្ខណៈជាប្រាក់បៀវត្សបន្ថែមដូចជាករណីប្រាក់បំណាច់ ដែលបានបើកអោយអាស្រ័យដោយ :

- ការខំប្រឹងប្រែង ឬ គុណភាពការងារដែលបានបំពេញដោយអ្នកបំរើការងារ (ប្រាក់បំណាច់ទិន្នផល ប្រាក់បំណាច់ចំពោះការខិតខំព្យាយាម ប្រាក់បំណាច់សមត្ថភាព បច្ចេកទេស ។ល។)
- លក្ខន្តិកៈបុគ្គលិក (ប្រាក់បំណាច់អតីតភាព ប្រាក់បំណាច់ឈប់សំរាកមានបៀវត្ស ប្រាក់បំណាច់ការងារក្រៅប្រទេស ប្រាក់បំណាច់បំពេញការងារនៅទីឆ្ងាយ ។ល។)

– លក្ខខណ្ឌដោយឡែកនៃការងារ (ប្រាក់បំណាច់មុខងារ ប្រាក់បំណាច់ទទួលខុសត្រូវ ប្រាក់បំណាច់ហានិភ័យ ប្រាក់បំណាច់ការងារពេលយប់ ។ល។)

២.៣. ចំណែកបន្ទាប់បន្សំផ្សេងៗទៀតគ្រប់ប្រភេទ

គឺជាចំនួនប្រាក់ ដែលបានបើកអោយទៅក្រៅប្រទេសដោយនិយោជកហើយដែល ផ្តល់ប្រយោជន៍ដោយផ្ទាល់ ឬ ដោយប្រយោលអោយនិយោជិក ។

(ឧទាហរណ៍ : ការផ្គត់ផ្គង់សេវា ឬ ទ្រព្យសកម្ម)

ប្រាក់បុរេប្រទាន ប្រាក់អោយខ្ចី ប្រាក់រំដោះនៃប្រាក់បៀវត្សដែលបានយល់ព្រមដោយនិយោជក អោយអ្នកបំរើការងារ ។ ប្រាក់ទាំងនេះត្រូវជាប់ពន្ធក្នុងខែដែលបានបើកនឹងត្រូវកាត់ចេញពីលាភការនៃខែដែលអ្នកបំរើការងារបានសងវិញ។

៣.អត្ថប្រយោជន៍ជាវត្ថុ

អត្ថប្រយោជន៍ជាវត្ថុ គឺ ជាប្រាក់បៀវត្សបំពេញបន្ថែមដែលត្រូវជាប់ពន្ធទៅតាមបទ បញ្ញត្តិនៃមាត្រាទី ១៤ ។

៣.១ បែបបទនៃការវាយតំលៃអត្ថប្រយោជន៍ជាវត្ថុ

អត្ថប្រយោជន៍ជាវត្ថុ ត្រូវបានវាយតំលៃ កាលបើអត្ថប្រយោជន៍ជាវត្ថុទាំងនេះជាផ្នូវនៃបន្ទុកផ្សេង ។ ដែលបានវាយតំលៃតាមរបៀបម៉ៅផ្តាច់ ។ ក្នុងករណីនេះ នៅក្នុងបញ្ជីគណនេយ្យរបស់សហគ្រាសគណនី ៦៤៧ «អត្ថប្រយោជន៍ជាវត្ថុ» ត្រូវចុះខាងឥណពន្ធ និង ត្រូវចុះខាងឥណទានគណនី ៧៩ «ផ្ទាស់បន្ទុក» ។

កាលណាអត្ថប្រយោជន៍ជាវត្ថុ ដែលបានយល់ព្រមអោយជាបន្ទុកដែលអាចកត់ពិនភាគបានហើយដែលបានប្រគល់អោយដោយតតិយជន គណនី ៦៤៧ «អត្ថប្រយោជន៍ជាវត្ថុ» ត្រូវចុះខាងឥណពន្ធ និង ត្រូវចុះខាងឥណទានគណនីដែលទទួលសេវាខាងក្រៅ (៦១) ។

ការវាយតំលៃនេះ ត្រូវធ្វើដោយនិយោជកក្រោមការទទួលខុសត្រូវផ្ទាល់របស់ខ្លួន និង ស្ថិតនៅក្រោមសិទ្ធិត្រួតពិនិត្យរបស់អង្គការពន្ធ ។

៣.២. អត្ថប្រយោជន៍ជាវត្ថុដែលបានផ្តល់អោយដោយញឹកញាប់អាចវាយតំលៃដូចតទៅ :

• លំនៅដ្ឋាន :

– ថ្លៃឈ្នួលប្រចាំខែដែលបង់ពិតប្រាកដដោយនិយោជកអោយម្ចាស់លំនៅដ្ឋាន

- តំលៃជួលប្រចាំខែ នៃលំនៅដ្ឋានប្រសិនបើលំនៅដ្ឋាននេះ ជាកម្មសិទ្ធិរបស់និយោជកដោយគិតតាមថ្លៃទីផ្សារសំរាប់ការជួលផ្ទះប្រហាក់ប្រហែលគ្នានេះ។

• បង្ការីម :

- ១/១២ នៃរំលស់ប្រចាំឆ្នាំដែលបានអនុវត្តក្នុងបញ្ជាពន្ធលើប្រាក់ចំណេញ

• ទឹក អគ្គិសនី :

- ចំនួនប្រាក់ប្រចាំខែដែលនិយោជកបានបង់

• អ្នកបំរើ :

- ចំណាយប្រចាំខែ បូកបន្ទុកជាយថាហេតុដែលភ្ជាប់ជាមួយនឹងប្រាក់បៀវត្ស

• រថយន្ត :

- ១/១២ នៃរំលស់ នៃធានារ៉ាប់រង នៃពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះ នៃសោហ៊ុយថែទាំ និង ថ្លៃសាំង ។

• ការកាត់យកមុនជាវត្ថុទ្រព្យសំភារៈ ឬ សេវា :

- ថ្លៃធម្មតានៃការលក់ទំនិញ ឬ ការផ្គត់ផ្គង់សេវាដែលបានកាត់យកមុន ។

ផ្នែកទី ៣ ចំណែកនៃលាភការដែលត្រូវបានលើកលែងពន្ធ

ចំណែកនៃលាភការ ដែលត្រូវលើកលែងពន្ធបានចែងយ៉ាងច្បាស់លាស់នៅក្នុង មាត្រា ១២ នៃច្បាប់ ។ ប៉ុន្តែផ្ទុយពីប្រាក់បំណាច់ដែលមានលក្ខណៈជាប្រាក់បៀវត្សបន្ថែមនោះ ត្រូវបន្ថែមក្នុងចំណែកដែលត្រូវបានលើកលែងពន្ធនូវគ្រប់ប្រាក់បំណាច់ ដែលគ្មានលក្ខណៈ ជាប្រាក់បៀវត្សបន្ថែម ។

១. ប្រាក់បំណាច់ដែលពុំមានលក្ខណៈជាប្រាក់បៀវត្សបន្ថែម

ពុំមែនជាប្រាក់បៀវត្សបន្ថែម គឺចំនួនប្រាក់ដែលបានបើកសំរាប់ជាសោហ៊ុយវិជ្ជាជីវៈដែលអ្នកបំរើការងារបានទទួលពិតប្រាកដដោយលក្ខខ័ណ្ឌពិសេសនៃការងារជាអាទិ អាចរួមបញ្ចូលជាប្រាក់បំណាច់ដែលត្រូវបានលើកលែងពន្ធចំពោះ :

- សោហ៊ុយសំរាប់សំលៀកបំពាក់ពិសេស ដែលចាំបាច់ខានពុំបាន ក្នុងការបំពេញសកម្មភាព ឬ ដែលប្រភេទមុខងារកំណត់អោយ ។
- ប្រាក់បំណាច់ម៉ៅផ្តាច់សំរាប់សោហ៊ុយបេសកកម្ម និង ផ្លាស់ប្តូរកន្លែង ។ មាត្រា ១២ បានចែងយ៉ាងច្បាស់លាស់នូវការលើកលែងពន្ធចំពោះប្រាក់បំណាច់ម៉ៅ ផ្តាច់ទាំងនេះ លើកលែងតែក្នុងករណីដែលប្រាក់បំណាច់នេះ

ត្រូវគ្នាជាមួយ នឹងប្រាក់សំណងនៃសោហ៊ុយពិត ប្រាកដបានចាយដោយអ្នកបំរើការងារ (មើលចំណុច ៣ បន្ទាប់ ដែលស្តីពីប្រាក់សំណងសោហ៊ុយពិតប្រាកដអោយអ្នកបំរើការងារដោយនិយោជក) ។

- សោហ៊ុយបន្ថែម នៃការផ្គត់ផ្គង់ម្ហូបអាហារដែលបានទទួលរងដោយអ្នកបំរើការងារ ដែលធ្វើការនៅលើការដ្ឋានឆ្ងាយ ។ ពីកន្លែងដែលគេធ្លាប់ធ្វើការជាធម្មតា ។
- សោហ៊ុយសំរាប់ឯកសារវិជ្ជាជីវៈ ដែលស្ថិតក្នុងក្របខ័ណ្ឌនៃការថែរក្សា ឬវិក្រឹតការ ចំណេះដឹង ។
- សោហ៊ុយបន្ថែម ដើម្បីសំអាតសំរាប់សកម្មភាពមួយចំនួន ដែលមានភាពគ្រោះថ្នាក់។

សរុបមក គឺ មិនគ្រប់គ្រាន់ទេដោយគ្រាន់តែអោយឈ្មោះហៅថា ប្រាក់បំណាច់ សំរាប់ជំនួសអោយពាក្យថាប្រាក់បៀវត្ស បុព្វលាភ ឬពាក្យផ្សេងទៀតដើម្បីបាន លើកលែងពន្ធលើប្រាក់បៀវត្សជាស្វ័យប្រវត្តិនោះ ។ និយោជកត្រូវចង្អុលបង្ហាញ តាមរបៀបមួយដែលមិនអាច ជជែកវែកញែកបានថា ប្រាក់បំណាច់ដែលនិយោជក បើកអោយអ្នកបំរើការងារជាសោហ៊ុយវិជ្ជាជីវៈពិសេសដែលបានទទួលយ៉ាងពិតប្រាកដដោយអ្នកបំរើការងារ ហើយចំនួនប្រាក់នេះ មិនមានលក្ខណៈជាប្រាក់បៀវត្សបន្ថែមដែលបានក្លែងបន្លំនោះទេ ។

ប៉ុន្តែប្រាក់បំណាច់ដែលបានឆ្លើយតបតាមនិយមន័យនេះ នឹងត្រូវបានលើកលែងពន្ធតែក្នុងករណី ដែលប្រាក់បំណាច់ទាំងនេះមានទំនាក់ទំនងជាមួយនឹងសារសំខាន់ នៃចំណាយដែលបានទទួលរងដោយអ្នកបំរើការងារ ។ ប្រសិនបើមានប្រាក់បំណាច់ដែលមាន ភស្តុតាងបង្ហាញខាងគោលការណ៍ហើយ ប៉ុន្តែខាងចំនួនមានការបំផ្លើសនោះ ចំណែកនៃប្រាក់បំណាច់ដែលមិនស្របទៅនឹងចំណាយវិជ្ជាជីវៈដែលបានទទួលយ៉ាងពិតប្រាកដ ដោយអ្នកបំរើការងារ គឺ ជាប្រាក់បៀវត្សបន្ថែមដែលត្រូវជាប់ពន្ធលើប្រាក់បៀវត្ស ។

២. ករណីពិសេសនៃប្រាក់បំណាច់ពីការបញ្ឈប់លែងអោយធ្វើការ

ប្រាក់បំណាច់ស្របច្បាប់នៃការបញ្ឈប់ដែលអោយធ្វើការ ដែលបានចែងក្នុងច្បាប់ការងារពុំមានលក្ខណៈជាប្រាក់ចំណូលទេ ។ ប្រាក់បំណាច់នេះ មានគោលដៅ

សំរាប់រ៉ាប់រងនូវប្រយោជន៍ដែលបានខូចខាតដោយហេតុមកពីការបញ្ឈប់អ្នកបំរើការងារពីការងាររបស់គេ ។ មាត្រា ១២ នៃច្បាប់បានចែងថា ប្រាក់បំណាច់ពីការបញ្ឈប់លែងអោយធ្វើការនេះ មិនត្រូវជាប់ពន្ធលើប្រាក់បៀវត្សឡើយ ។ ពិតប្រាកដណាស់ ចំនួនប្រាក់នៃប្រាក់បំណាច់នេះត្រូវ មានទំនាក់ទំនងជាមួយប្រាក់បៀវត្សពីមុន និងត្រូវគិតដល់រយៈពេលនៃការធ្វើការ ដែលគេបានធ្វើការកន្លងមកមុនពេលបញ្ឈប់ដែលអោយធ្វើការ ។

៣. ប្រាក់សងដោយពិតប្រាកដនូវសោហ៊ុយវិជ្ជាជីវៈ

ប្រាក់សងដោយពិតប្រាកដនូវសោហ៊ុយដែលបានចាយដោយអ្នកបំរើការងារសំរាប់ជាប្រយោជន៍និយោជកពុំមែនជាចំណែកនៃលាភការទេ ។ ប្រាក់សងដោយពិតប្រាកដ នេះមិនត្រូវជាប់ពន្ធឡើយ ។ ឧទាហរណ៍ដូចជាករណីប្រាក់សងនូវសោហ៊ុយបដិសណ្ឋារកិច្ច បេសកម្ម និង ផ្លាស់កន្លែង ។

ប៉ុន្តែមាត្រា ១២ នៃច្បាប់បានកំណត់ថា ត្រូវបំពេញលក្ខខ័ណ្ឌ ៣ ដើម្បីត្រូវបានលើកលែងពន្ធចំពោះប្រាក់សងនូវសោហ៊ុយនេះគឺ :

- សោហ៊ុយត្រូវបានចាយ ដើម្បីជាប្រយោជន៍ផ្ទាល់ និង ដាច់ខាតរបស់សហគ្រាស និង មិនមែនសំរាប់បំពេញតំរូវការឯកជនរបស់អ្នកបំរើការងារ (ទោះជាអ្នកដឹកនាំ ឬ មិនមែនអ្នកដឹកនាំរបស់សហគ្រាសក៏ដោយ) : ឧទាហរណ៍ ការធ្វើដំណើរជាឯកជនក្រោមផ្លាក ទៅចូលរួមប្រជុំជាដំណើរសិក្សាទស្សនាការរបស់អតិថិជន ឬអ្នកផ្គត់ផ្គង់ បដិសណ្ឋារកិច្ចនៃទំនាក់ទំនងបុគ្គល ។ល។
- សោហ៊ុយដែលបានសងមិនត្រូវមានលក្ខណៈបំផ្លើស ឬ ស្ទុកស្តម្ភហួសហេតុបើគិតដល់សារសំខាន់នៃសហគ្រាស ។
- សោហ៊ុយដែលបានសងត្រូវមានភស្តុតាងបង្ហាញដោយវិក័យប័ត្រលំអិត និងដែលបានទូទាត់ស្រេចបាច់ ហើយដែលធ្វើក្នុងនាមអ្នកទទួលប្រយោជន៍នៃប្រាក់សំណង ។

ប្រាក់សងនូវសោហ៊ុយពិតប្រាកដ ដែលមិនឆ្លើយតាមទៅនឹងលក្ខខ័ណ្ឌទាំងនេះ ត្រូវជាប់ពន្ធនូវពន្ធលើប្រាក់បៀវត្ស ។

៤. លាភការបំពេញបន្ថែមមានលក្ខណៈជាសង្គមកិច្ច

ប្រាក់បំពេញបន្ថែមមានលក្ខណៈជាសង្គមកិច្ចនេះ គឺ សំដៅដល់គ្រប់ប្រាក់

ដែលបានទទួលសំរាប់បំពេញបន្ថែមប្រាក់បៀវត្ស ដោយគិតទៅដល់ស្ថានភាពគ្រួសារ ស្ថានភាពសុខ ភាព និង អាយុនៃអ្នកជាប់ពន្ធ និងសមាជិកគ្រួសាររបស់គេ។ ត្រូវ បានលើកលែងពន្ធក្នុងបរិបទនេះ នូវប្រាក់វិភាជន៍គ្រួសារ ប្រាក់វិភាជន៍សំរាប់វិគលភាពប្រាក់អោយថែមសំរាប់ព្រឹត្តិការណ៍នានាក្នុងគ្រួសារ (សំរាលកូន មង្គលការ ស្លាប់ ។ល។)

៥.ការផ្គត់ផ្គង់ដោយឥតគិតថ្លៃឬយកថ្លៃឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន និង បរិក្ខារវិជ្ជាជីវៈពិសេស :

ផ្នែកទី ៤ ការកំណត់មូលដ្ឋានគិតពន្ធ

១-ការកំណត់មូលដ្ឋានដុលគិតពន្ធ :

មូលដ្ឋានដុលសំរាប់គិតពន្ធលើប្រាក់បៀវត្ស សរុបរួមមាន :

១.១ ចំនួនសរុបដែលបានបង្កើតឡើងដោយ :

- ចំនួនប្រាក់បៀវត្សប្រចាំខែពិត។ (ប្រាក់បៀវត្សជាមូលដ្ឋាន) ។
- ប្រាក់បៀវត្សបន្ថែម (ប្រាក់ម៉ោងបន្ថែម បុព្វលាភ ប្រាក់អោយថែមផ្សេងៗ ប្រាក់បំណាច់ ។ល។)
- អត្ថប្រយោជន៍ជាវត្ថុ

១.២ ដកចំនួនប្រាក់ដែលបានកាត់ទុកជាកាតព្វកិច្ច អនុវត្តតាមច្បាប់សង្គមកិច្ចដែល គ្រប់គ្រងអ្នកបំរើការងារប្រសិនបើត្រូវមានការកាត់ទុកនេះ (មាត្រា ១៤.១ នៃច្បាប់) ឧទាហរណ៍ក្នុងក្របខ័ណ្ឌនៃច្បាប់បរទេស ។

២.ការបន្ថយមូលដ្ឋានកំណត់ពន្ធសំរាប់កូនជាអនីតិជននៅក្នុងបន្ទុក

មាត្រា១៦ វាក្យខ័ណ្ឌ ១.១ នៃច្បាប់បានចែងថា ផ្អែកតាមការបង្ហាញភស្តុតាងអំពីស្ថានភាពគ្រួសាររបស់ខ្លួនអ្នកបំរើការងារដែលមានកូនជាអនីតិជន នៅក្នុងបន្ទុកនាពេលដែល ត្រូវបង់ពន្ធត្រូវបានទទួលប្រយោជន៍ពីការបន្ថយមូលដ្ឋានកំណត់ពន្ធប្រចាំខែ នូវចំនួន ៧៥.០០០ រៀលសំរាប់កូនម្នាក់ ។

អ្នកបំរើការងារ និង និយោជករបស់គេ ត្រូវបង្ហាញភស្តុតាងសំរាប់បញ្ជាក់អំពីការ មានកូនអនីតិជននៅក្នុងបន្ទុកនេះ ដែលអនុញ្ញាតអោយអ្នកបំរើការងារមានសិទ្ធិកាត់បន្ថយមូលដ្ឋានកំណត់ពន្ធ ។ សម្ព័ន្ធជាបុគ្គភាព ត្រូវតែបង្កើតអោយមានយ៉ាងពិតប្រាកដចំពោះ អ្នកបំរើការងារ ឬ សហព័ទ្ធរបស់គេ (ក្នុងករណីកូន

ក្មួន ខាន់ស្លា ឬ កូនរបស់ប្រពន្ធ) តាមរយៈការបង្កើតបញ្ជីជាតិ ។

អត្ថប្រយោជន៍សារពើពន្ធដែលជាប់ទាក់ទងជាមួយនឹងកូនជាអនីតិជននៅក្នុងបន្ទុកនេះ ត្រូវបញ្ចាក់នៅខែដែលកូនអនីតិជននេះ ដល់អាយុក្លាយជានីតិជន គឺ ដល់អាយុ ១៨ ឆ្នាំ ។ ប្រសិនបើជាកូនដែលមានសញ្ជាតិបរទេស ត្រូវប្រកាន់យក អាយុ ១៨ ឆ្នាំ នេះជាកំណត់។

ក្នុងការអនុវត្តន៍សិទ្ធិកាត់បន្ថយមូលដ្ឋាន កំណត់ពន្ធនឹងត្រូវអស់នៅក្នុងខែបន្ទាប់ពីខែ ដែលកូននៅក្នុងបន្ទុកមានអាយុជានីតិជន ។

ជំពូកទី ៣

ដែនដីនៃពន្ធ

វៀរលែងតែមានបទបញ្ញត្តិពិសេសជាអាទិកិច្ចព្រមព្រៀងសារពើពន្ធអន្តរជាតិ វិធានអំពីដែនដីនៃពន្ធលើប្រាក់បៀវត្ស ដែលបានចែងក្នុងមាត្រា ១១ នៃច្បាប់មានដូចតទៅ :

ផ្នែកទី ១ សកម្មភាពបំពេញការងារនៅកម្ពុជា

ពន្ធត្រូវកំណត់ចំពោះប្រាក់បៀវត្សដែលបានទទួលជាថ្នូរ នៃសកម្មភាពដែលបានបំពេញនៅក្នុងសហគ្រាសនៅកម្ពុជា ។ តាមគោលការណ៍នេះ ពន្ធអាចទារបានដោយពុំគិតអំពី :

- សញ្ជាតិនៃអ្នកបំរើការងារ
- ទីកន្លែងស្នាក់នៅអចិន្ត្រៃយ៍នៃអ្នកបំរើការងារ និង គ្រួសាររបស់គេ
- សញ្ជាតិ និង កន្លែងទីស្នាក់ការរបស់សហគ្រាស ឬ គ្រឹះស្ថានជាគោលដើមរបស់សហគ្រាស ។
- ទីកន្លែងបើកប្រាក់បៀវត្ស
- ដើមកំណើតនៃប្រាក់ដែលបានបើក (ការផ្គត់ផ្គង់ហិរញ្ញវត្ថុរបស់ជាតិ ឬ ពីក្រៅ)

ម៉្យាងទៀត ពន្ធនេះអាចទារបានពីលាភការទាំងអស់ដែលបានផ្តល់អោយអ្នកបំរើការងារ ដោយគិតបញ្ចូលទាំងចំណែកដែលបានបើកអោយទៅបរទេសជាពិសេសចំពោះអ្នកបំរើការងារដែលមានលក្ខណៈជានិវាសជន ។ ក្នុងសម្មតិកម្មនេះ ត្រូវតែធ្វើការប្តូរប្រាក់លាភការ ដែលបើកជារូបិយប័ណ្ណបរទេសជាប្រាក់រៀល

ទៅតាមអត្រាប្តូរប្រាក់ជាផ្លូវការ ។

ផ្នែកទី ២ សកម្មភាពបំរើការងារនៅក្រៅកម្ពុជា

មាត្រា ១១ នៃច្បាប់បានចែងថា សកម្មភាពបំរើការងារនៅក្រៅកម្ពុជា ត្រូវជាប់ពន្ធលើប្រាក់បៀវត្សកាលបើនិយោជកមានលំនៅនៅកម្ពុជា ។

ផ្អែកតាមវិធានដែលត្រូវអនុវត្តក្នុងបញ្ហាពន្ធលើប្រាក់ចំណេញ គឺ ត្រូវទុកជាអ្នកមានលំនៅនៅកម្ពុជា នូវសហគ្រាសដែលមានគ្រឹះស្ថានអចិន្ត្រៃយ៍នៅកម្ពុជា ។

សូមរំលឹកថា គ្រឹះស្ថានអចិន្ត្រៃយ៍អាចជា :

- ទីស្នាក់ការនៃទីចាត់ការរបស់សហគ្រាស
- រោងចក្រ រោងជាង ការដ្ឋាន
- ការិយាល័យ ឬ កន្លែងទិញឬលក់
- សាខា ឃ្លាំង ទីភ្នាក់ងារ
- អណ្តូងរ៉ែ កន្លែងយកថ្មី ឬ កន្លែងសំរាប់ធ្វើនិស្សារណកម្មធនធានធម្មជាតិ
- និង ជាទូទៅរាល់ឋបនភ័ណ្ឌនៅនឹង ដែលសហគ្រាសបំពេញសកម្មភាពរបស់ខ្លួនទាំងស្រុង ឬ ដោយផ្នែកខ្លះ នៃសកម្មភាពរបស់ខ្លួន ។

ជំពូកទី ៤

ការគណនាប្រាក់ពន្ធ

តារាងអត្រានៃពន្ធលើប្រាក់បៀវត្សដែលត្រូវអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៥ គឺមានដូចតទៅ : (មាត្រា ១៦ នៃច្បាប់)

ភាគបៀវត្សប្រចាំខែត្រូវជាប់ពន្ធ				អត្រាពន្ធ
ពី	១៛០០	ដល់	៧៥០.០០០៛០០	០ %
ពី	៧៥០.០០១៛០០	ដល់	១.០០០.០០០៛០០	៥ %
ពី	១.០០០.០០១៛០០	ដល់	១០.០០០.០០០៛០០	១០ %
ពី	១០.០០០.០០១៛០០	ដល់	២០.០០០.០០០៛០០	១៥ %
		លើសពី	២០.០០០.០០០៛០០	២០%

ផ្នែកទី១ . តារាងអត្រាពន្ធ គឺជាតារាងអត្រាពន្ធប្រចាំខែ

លាភការដែលពាក់ព័ន្ធនឹងរយៈកាលធ្វើសកម្មភាពតិចជាងមួយខែ ត្រូវតែបំបែរអោយជាប្រចាំខែ (ឧទាហរណ៍ៈ ប្រាក់បៀវត្សប្រចាំថ្ងៃ សប្តាហ៍ ពីរសប្តាហ៍) ។

ប្រាក់ពន្ធកាត់ទុកដែលពាក់ព័ន្ធទៅនឹងចំនួនប្រាក់ដែលត្រូវបំលែងអោយទៅជាចំនួនប្រចាំខែ គឺបានមកពីផលដែលកើតមានរវាងចំនួនថ្ងៃនៃរយៈកាលធ្វើការងារដែលបានបើកប្រាក់ និង ៣០ ថ្ងៃ (រយៈពេលមធ្យមសំរាប់មួយខែ) នោះអាចបានប្រាក់ពន្ធកាត់ទុកដែលត្រូវបង់ ។

__ឧទាហរណ៍អនុវត្តន៍__ :

អ្នកបំរើការងារម្នាក់បានទទួលប្រាក់បៀវត្ស ១៥ ថ្ងៃម្តង មានចំនួន ៩.០០០.០០០ រៀល ។ ការគណនាអំពី ប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវកាត់ទុកត្រូវធ្វើដូចតទៅ ÷

- ប្រាក់បៀវត្សប្រចាំខែ គឺ : ៩.០០០.០០០ × ២ = ១៨.០០០.០០០រៀល ។
- បើអនុវត្តតារាងអត្រាពន្ធប្រចាំខែគឺពន្ធត្រូវមានចំនួន ២.១១២.៥០០ រៀល។
- ប្រាក់កាត់ទុកដែលត្រូវអនុវត្តលើលាភការដែលបានបើកក្នុង ១៥ ថ្ងៃម្តង នោះ ត្រូវមានចំនួនស្មើនឹងពាក់កណ្តាល គឺ ១.០៥៦.២៥០ រៀល ។

ផ្នែកទី២ . តារាងអត្រាពន្ធ គឺជាតារាងអត្រាពន្ធកំណើន

គឺជាកំណើនតាមភាគនៃប្រាក់ចំណូល ។

__ឧទាហរណ៍អនុវត្តន៍__ :

អ្នកបំរើការងារម្នាក់ មានលាភការប្រចាំខែត្រូវជាប់ពន្ធ មានចំនួន ២០.០០០.០០០ រៀល ។ ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់ ត្រូវគិតដូចតទៅ ÷

- ក្រោម ៧៥០.០០០រៀល = ០ រៀល
- រវាង ៧៥០.០០១រៀល និង ១.០០០.០០០រៀល = ១២.៥០០ រៀល
  (២៥០.០០០រៀល × ៥ %)
- រវាង ១.០០០.០០១រៀល និង១០.០០០.០០០រៀល = ៩០០.០០០ រៀល
  (៩.០០០.០០០ រៀល × ១០ %)
- រវាង ១០.០០០.០០១រៀល និង ២០.០០០.០០០រៀល = ១.៥០០.០០០ រៀល
  (១០.០០០.០០០ រៀល × ១៥ %)

សរុបត្រូវបង់ = ២.៤១២.៥០០ រៀល

ផ្នែកទី៣ . រូបមន្តសំរាប់ធ្វើអោយមានការងាយស្រួលក្នុងការគណនាពន្ធ

គេអាចគណនារកចំនួនប្រាក់ពន្ធ ដែលត្រូវកាត់ទុកដោយអនុវត្តរូបមន្តដូចខាងក្រោម ÷

- បើលាភការ (ល) មានចំនួនមិនលើស ៧៥០.០០០ រៀល ពន្ធត្រូវស្មើនឹង 0
- បើលាភការ (ល) មានចំនួនលើសពី ៧៥០.០០០ រៀល នឹងតិចជាង ឬ ស្មើ ១.០០០.០០០ រៀល ពន្ធត្រូវស្មើនឹង : ១២.៥០០–0,0៥ (១.០០០.០០០–ល)
- បើលាភការ (ល) មានចំនួនច្រើនជាង ១.០០០.០០០ រៀល និង តិចជាង ឬ ស្មើ ១០.០០០.០០០ រៀល ពន្ធត្រូវស្មើនឹង : ៩១២.៥០០–0,១០ (១០.០០០.០០០–ល)
- បើលាភការ (ល) មានចំនួនច្រើនជាង ១០.០០០.០០០ រៀល និងតិចជាង ឬ ស្មើ ២០.០០០.០០០ រៀល ពន្ធត្រូវស្មើនឹង : ២.៤១២.៥០០ – 0,១៥ (២០.០០០.០០០– ល)
- បើលាភការ (ល) មានចំនួនច្រើនជាង ២០.០០០.០០០ រៀល ពន្ធត្រូវស្មើនឹង : ២.៤១២.៥០០ + 0,២0 (ល – ២០.០០០.០០០) ។

ជំពូកទី៥

ហេតុបណ្តាលអោយជាប់ពន្ធ

តាមបទបញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែល ស្តីពីការបង្កើតពន្ធលើប្រាក់បៀវត្សនោះ ហេតុបណ្តាលអោយជាប់ពន្ធគឺជាការបើកប្រាក់លាភការដែលជាគ្រាក់បៀវត្ស ។

ការបញ្ជាក់ផ្សេងៗ :

- ការកត់ត្រានៅខាងឥណទាន នៃគណនីចរន្តរបស់សមាគតនូវចំនួនប្រាក់ នៃប្រាក់បៀវត្ស គឺជាការបើកប្រាក់ បៀវត្សទោះបីសមាគតនោះទុកចំនួនប្រាក់នេះអោយក្រុមហ៊ុន ប្រើប្រាស់ក៏ដោយ ។

ប៉ុន្តែសូមបញ្ជាក់ថា ដោយគ្មានច្បាប់ចែងអំពីក្រុមហ៊ុនការកំណត់លក្ខណៈសារពើពន្ធនៃលាភការរបស់ សមាគតឃើញថាមានការពិបាក ។ ដូចនេះការបញ្ជាក់នេះត្រូវបានទាញយកមកពីធានគណនេយ្យ ដែលអាចអោយចាត់ទុកថាជាលាភការដែលបានកត់ត្រាខាងឥណទាននៃគណនីចរន្តរបស់សមាគត ។

- អត្ថប្រយោជន៍ជាវត្ថុត្រូវភ្ជាប់ជាមួយ នឹងលាភការ នៃខែដែលអ្នកបំរើការងារ

បានទទួលអត្ថប្រយោជន៍ជាវត្ថុ ទាំងនេះ ។

ជំពូកទី៦

កាតព្វកិច្ចរបស់និយោជក

សហគ្រាសសាធារណៈ និង សហគ្រាសឯកជន ទោះបីជារូបវន្តបុគ្គលក្តី ឬ ជានីតិបុគ្គលក្តីត្រូវកាត់ទុកប្រាក់ពន្ធលើប្រាក់ បៀវត្សសំរាប់ជាប្រយោជន៍ដល់រតនាគារជាតិនា ពេលបើកបៀវត្សម្តង ៗ (មាត្រា ១៩ នៃច្បាប់) ។

ស្របជាមួយនឹងការកាត់ទុកប្រាក់ពន្ធលើប្រាក់បៀវត្ស ដែលជាប្រាក់ពន្ធរបស់រដ្ឋនោះនិយោជកមានកាតព្វកិច្ចដូចតទៅ ÷

ផ្នែកទី១. ការកាន់បញ្ជីប្រចាំខែដែលមានចុះចំនួនប្រាក់បានបើក និងចំនួនប្រាក់បានកាត់ទុក

បញ្ជីនេះមានចែងក្នុង មាត្រា ២១ នៃច្បាប់រួចហើយ គឺត្រូវប្រើប្រាស់សំរាប់ជាមូលដ្ឋានក្នុងការបង្កើត លិខិតប្រកាសប្រចាំខែនូវពន្ធលើប្រាក់បៀវត្ស ។ ត្រូវកត់ត្រាបញ្ជីសំរាប់អ្នកបំរើការងារម្នាក់ៗនូវ ÷

- នាម និង គោត្តនាម
- លំនៅដ្ឋាន
- ប្រភេទការងារ
- ថ្ងៃចូលបំរើការ និង ថ្ងៃឈប់ពីការងារ ប្រសិនបើមាន ឬ ថ្ងៃផ្អាកសកម្មភាព
- ចំនួនប្រាក់ដុលនៃលាភការជាមូលដ្ឋានសុទ្ធសាធ
- ចំនួនប្រាក់វាយលំអិតនៃលាភការបន្ទាប់បន្សំ (ម៉ោងបន្ថែមប្រាក់បំណាច់បុព្វលាភប្រាក់សងម៉ៅការនូវ ចំណាយ ប្រាក់អោយថែមជារង្វាន់ផ្សេងៗ)
- ប្រភេទ និង ចំនួនប្រាក់ខែអត្ថប្រយោជន៍ ដែលបានវាយតំលៃតាមតំលៃពិតប្រាកដរបស់វា
- លាភការរំលឹក
- ប្រាក់បុរេប្រទាន ប្រាក់អោយខ្ចី និង ប្រាក់រំដោះដែលបានទទួល ឬ ដែលបានសង
- ប្រាក់កាត់ទុកជាកាតព្វកិច្ចសំរាប់សង្គមកិច្ច
- មូលដ្ឋានគិតពន្ធ

- ប្រាក់ពន្ធដែលបានកាត់ទុក
- ប្រភេទ និង ចំនួនប្រាក់នៃចំណែកលាភការនិមួយៗ ដែលបានចាត់ទុកថា មិនត្រូវជាប់ពន្ធ

បញ្ជីគល់បញ្ជីបើកប្រាក់អោយអ្នកបំពេញការងារ សក្ខីប័ត្រវាយតំលៃអត្ថប្រយោជន៍ ជាវត្ថុប្រាក់ សំណងពិត ប្រាកដនូវចំណាយ និង រាល់ចំណែកលាភការអោយរួចពន្ធ បង្កាន់ដៃបើកប្រាក់ ត្រូវរក្សាទុករហូតដល់ផុត ឆ្នាំទី ៣ បន្ទាប់ពីឆ្នាំដែលបានអនុវត្តការកាត់ទុកនូវប្រាក់ពន្ធ ។

ផ្នែកទី២ . ការបង់ប្រាក់ប្រចាំខែនូវប្រាក់ពន្ធលើប្រាក់បៀវត្សរ៍ដែលបានកាត់ទុក

គឺជាគោលការណ៍ទូទៅ ដែលបានកំណត់ដោយ មាត្រា ២០ នៃច្បាប់ ។ មាត្រានេះបានចែងថា ប្រាក់ពន្ធដែលបានកាត់ទុកពីប្រាក់បៀវត្សនៃខែណាមួយត្រូវបង់យ៉ាងយឺតនៅថ្ងៃទី ១៥ ខែបន្ទាប់ជូនទៅផ្នែកពន្ធនៅ ទីកន្លែងនៃលំនៅដ្ឋាន ឬ គ្រឹះស្ថានចម្បងនៃបុគ្គលដែលបានកាត់ទុកប្រាក់ពន្ធនេះ (ចំពោះសញ្ញាណលំនៅដ្ឋាននេះ សូមមើលផ្នែកទី ២ នៃជំពូកទី ៣ ដែលនិយាយអំពីសញ្ញាណដែនដីនៃពន្ធ) ។

មាត្រា ១៩ នៃច្បាប់បានកំណត់អំពីគោលការណ៍នៃការទទួលខុសត្រូវរបស់និយោជកដែលមាន កាតព្វកិច្ចបំពេញកិច្ចការចាត់ទុកប្រាក់ពន្ធនាពេលបើកប្រាក់បៀវត្ស ។

ផ្នែកទី៣ . ការលើកលែងនូវគោលការណ៍នៃការបង់ប្រាក់ពន្ធប្រចាំខែ

ច្បាប់ចែងអោយមានករណីតែមួយដែលការកំណត់ពន្ធ និង ការបង់ប្រាក់ពន្ធមិនត្រូវបានអោយធ្វើតាមសាមយិកភាពប្រចាំខែ គឺ ÷

- ផ្អែកតាម មាត្រា ១៦-២ នៃច្បាប់ ជនជាតិខ្មែរ និង និវាសជនបរទេសដែលបានទទួលនៅក្រៅកម្ពុជា នូវប្រាក់បៀវត្សដែលបានបង់ពន្ធតាមបទបញ្ញត្តិនៃច្បាប់បរទេសត្រូវបានទទួលប្រយោជន៍ ក្នុងលក្ខខ័ណ្ឌដែលមានការបញ្ជាក់អះអាងអំពីការបង់ប្រាក់ពន្ធនេះ នូវឥណទានពន្ធមួយដែលត្រូវដកចេញពីប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់ ។
- ឥណទានពន្ធដែលអាចដកចេញអាស្រ័យដោយប្រាក់បៀវត្សដែលបានទទួល និង បានបង់ពន្ធនៅ បរទេសត្រូវគណនាដោយអនុវត្តតារាងអត្រាពន្ធកម្ពុជាលើប្រាក់បៀវត្សដែលបានទទួលនៅបរទេសនេះ (មាត្រា ១៦-២២) ។

ប្រភេទប្រាក់ចំណូលផ្សេងៗទៀត ដែលត្រូវទទួលនៅបរទេសមិនអាចត្រូវបានយកមកសំរាប់កំណត់ឥណទានពន្ធឡើយ ។

– ជាបដិភាគ ប្រាក់បៀវត្សបរទេសត្រូវជាប់ពន្ធនៅកម្ពុជា ដូចជាប្រាក់បៀវត្សកម្ពុជាដែរតាមតារាងអត្រាពន្ធ ដូចគ្នា ។

បទបញ្ញត្តិទាំងនេះអាចអនុវត្តបាន វៀរលែងតែមានបទបញ្ញត្តិផ្ទុយដែលនឹងអាចមាននៅក្នុងកិច្ចព្រមព្រៀងសារពើពន្ធអន្តរជាតិ រវាងប្រទេសកម្ពុជាជាមួយប្រទេសផ្សេងៗ ។

ក្នុងសម្មតិកម្ម ដែលប្រាក់បៀវត្សបរទេសត្រូវជាប់ពន្ធនៅកម្ពុជានោះការកំណត់ប្រាក់ពន្ធត្រូវបានលើកពេលពីព្រោះពុំមានលទ្ធភាពគិតគូរប្រាក់ពន្ធតាមសាមយិកភាពប្រចាំខែបានឡើយ ។

ដើម្បីអោយអ្នកបំរើការងារ ដែលមានការពាក់ព័ន្ធអាចរៀបចំសំណុំឯកសារចាំបាច់សំរាប់គិតគូរប្រាក់ពន្ធ នោះការកំណត់ និងការបង់ប្រាក់ពន្ធត្រូវធ្វើក្នុងអំឡុងនៃ ឆ្នាំស៊ីវិលដែលជាឆ្នាំបន្ទាប់ពីឆ្នាំដែលបានទទួលប្រាក់បៀវត្សបរទេស ។ ហេតុនេះ ការបង់ប្រាក់ពន្ធត្រូវធ្វើយ៉ាងយឺតបំផុតនៅថ្ងៃ ៣១ ខែ ធ្នូ នៃឆ្នាំបន្ទាប់នោះ ។

ឧទាហរណ៍នៃការកំណត់ពន្ធ :

អ្នកបំរើការងារម្នាក់ បានធ្វើការ ៨ ខែនៅកម្ពុជាដោយមានលាភការប្រចាំខែចំនួន ១០.០០០.០០០ រៀល ។ អ្នកបំរើការងារនេះគាត់បានបំពេញកិច្ចការក្នុងកំឡុងនៃឆ្នាំដដែលនេះនូវសកម្មភាពបំរើការងារដែលមានរយៈពេលពីរខែនៅបរទេសដោយមានប្រាក់បៀវត្សប្រចាំខែ ក្រោយពីបានប្តូរជាប្រាក់រៀលរួចហើយមានចំនួន ៦.០០០.០០០ រៀល ។

ប្រតិបត្តិការដែលត្រូវធ្វើមានបន្តបន្ទាប់ដូចតទៅ ÷

១. ការកំណត់មូលដ្ឋានគិតពន្ធនៅកម្ពុជា

(៨ ខែ × ១០.០០០.០០០ រៀល) + (២ ខែ × ៦.០០០.០០០ រៀល)

= ៩២.០០០.០០០ រៀល

គឺជាមធ្យមមានប្រាក់បៀវត្សប្រចាំខែចំនួន = ៩.២០០.០០០ រៀល ។

២.ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សរ៍ដែលត្រូវបង់ពន្ធនៅកម្ពុជាមុនពេលកាត់ឥណទានពន្ធ

សំរាប់មួយខែ (អនុវត្តរូបមន្តបំព្រួញ នៃតារាងអត្រាពន្ធ) មើលជំពូកទី .៤ ផ្នែកទី៣ ។

លាភការ (ល) ចំនួន ៩.២០០.០០០ រៀល គឺច្រើនជាង ១.០០០.០០០ រៀល និង តិចជាង ១០.០០០.០០០ រៀល ។

រូបមន្តដែលត្រូវអនុវត្តគឺ ÷

៩១២.៥០០ – ០,១០ (១០.០០០.០០០ – ល) ឬ ៩១២.៥០០ – ០,១០ (១០.០០០.០០០ – ៩.២០០.០០០) = ៨៣២.៥០០ រៀល សំរាប់ ១០ ខែ ប្រាក់ពន្ធដុលគឺមានចំនួន ៨.៣២៥.០០០ រៀល ។

៣.ការកំណត់ឥណទានពន្ធ

ផ្អែកតាមមាត្រា ១៦–២.២ នៃច្បាប់ ឥណទានពន្ធដែលអាចដកចេញត្រូវបានកំណត់ដោយអនុវត្តតារាង អត្រាពន្ធលើប្រាក់បៀវត្សកម្ពុជាចំពោះប្រាក់បៀវត្សដែលបានទទួលនៅបរទេស ។

ឥណទានពន្ធដែលអាចដកចេញ គឺមានដូចតទៅ ÷

សំរាប់មួយខែ (អនុវត្តរូបមន្តបំព្រួញលើតែប្រាក់បៀវត្សប្រចាំខែដែលបានទទួលនៅបរទេសមានចំនួន (៦.០០០.០០០ រៀល) គឺអនុវត្តដដែលដូចខាងលើ÷

៩១២.៥០០ – ០,១០ (១០.០០០.០០០ –៦.០០០.០០០) = ៥១២.៥០០ រៀល សំរាប់ពីរខែ ឥណទាន ពន្ធត្រូវជា ១.០២៥.០០០ រៀល (៥១២.៥០០×២)

៤. ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សកម្ពុជា

ប្រាក់ពន្ធដុល – ឥណទានពន្ធ គឺ :

៨.៣២៥.០០០ – ១.០២៥.០០០ = ៧.៣០០.០០០ រៀល

គួរចំណាំថា ប្រាក់ពន្ធត្រូវបានគណនាលើប្រាក់បៀវត្សសរុបដែលបានទទួលក្នុងកំឡុងពេលមួយឆ្នាំ ប៉ុន្តែជានិច្ចកាល ត្រូវអនុវត្តតាមតារាងអត្រាពន្ធប្រចាំខែ ។

កំណត់សំគាល់ :

– ភ្នាក់ងារដែលទទួលបន្ទុកពិនិត្យបញ្ជាក់ការកំណត់ប្រាក់ពន្ធ ត្រូវមានគ្រប់ឯកសារ ដែលអាចបញ្ជាក់បានថា ឥណទានពន្ធត្រូវបានគណនាត្រឹមត្រូវ ។

- អនុលោមតាមមាត្រា ១៦-២.២ នៃច្បាប់ គឺក្រោយពីការដាក់ចេញ នូវឥណទានពន្ធបើកត់សំគាល់ឃើញមានចំនួនលើសនៃឥណទានពន្ធចំនួនលើសនេះមិនត្រូវបានអនុញ្ញាតអោយសងវិញ ឬ បង្វិលអោយវិញឡើយ ។ ដូចនេះ រាល់ចំនួនលើសនៃឥណទានពន្ធត្រូវខាតបង់ទាំងស្រុង ។

ផ្នែកទី៤ : ការដាក់លិខិតប្រកាសសារពើពន្ធ

ការបង់ប្រាក់ពន្ធដែលបានកាត់ទុកត្រូវមានភ្ជាប់ជាមួយការដាក់លិខិតប្រកាសសារពើពន្ធអំពីពន្ធ លើប្រាក់បៀវត្សតាមគំរូដែលអង្គការពន្ធបានផ្តល់ជូន ។ លិខិតប្រកាសសារពើពន្ធទាំងនេះអាចត្រូវបាន ត្រួតពិនិត្យ និង ជាកម្មវត្ថុនៃនីតិវិធីក្នុងការកំណត់ពន្ធឡើងវិញប្រសិនបើមាន ។

ផ្អែកតាមមាត្រា ២៣ នៃច្បាប់ នីតិវិធីក្នុងការកំណត់ពន្ធឡើងវិញ ដែលបានចែងក្នុងមាត្រា ២៤ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ គឺអាចអនុវត្តបាន ។ នីតិវិធីក្នុងការកំណត់ពន្ធឡើងវិញនេះត្រូវ បានអនុវត្តកាលបើអង្គការពន្ធត្រូវកែប្រែមូលដ្ឋានកំណត់ពន្ធដែលមាននៅលើលិខិតប្រកាសសារពើពន្ធ ។

ផ្អែកតាមមាត្រា ២៤ នៃច្បាប់ នីតិវិធីក្នុងការកំណត់ពន្ធជាឯកតោភាគីរបស់អង្គការពន្ធ ដែលបានចែងក្នុងមាត្រា ៥៨ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលបាននិយាយខាងលើក៏អាចអនុវត្តបានដូចគ្នា ដែរកាលបើនិយោជកមិនបានដាក់លិខិតប្រកាសសារពើពន្ធ ។ ប៉ុន្តែការដាក់អោយដំណើរការ នូវនីតិវិធីនៃការកំណត់ពន្ធជាឯកតោភាគីនេះ ត្រូវធ្វើក្រោយពីការផ្ញើលិខិតរំលឹក ។ គឺចំពោះករណីដែលនិយោជកមិនបានដាក់លិខិតប្រកាសក្នុងរយៈពេលថ្មីកំណត់ដោយលិខិតរំលឹក តែប៉ុណ្ណោះដែលអង្គការពន្ធត្រូវធ្វើការកំណត់ពន្ធជាឯកតោភាគី ។

ទោសទណ្ឌផ្សេងៗដែលត្រូវអនុវត្ត ដោយអនុលោមតាមមាត្រា ២២ នៃច្បាប់នោះ គឺជាទោសទណ្ឌ ដែលបានចែងក្នុងមាត្រា ៥៧ មាត្រា ៥៩ និង មាត្រា ៦០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ។

ទាក់ទងទៅនឹងការប្រមូលពន្ធដោយបង្ខំ នូវពន្ធលើប្រាក់បៀវត្សនិយោជកនៅកម្ពុជា និង អ្នកបំរើការងារត្រូវទទួលខុសត្រូវរួមគ្នាក្នុងការបង់ពន្ធលើប្រាក់បៀវត្សនេះ មានន័យថាក្នុងករណីមានការភ្លាំងភ្លាត់របស់អ្នកជំពាក់ពន្ធស្របច្បាប់ដែល

ជានិយោជកនោះ ផ្នែកប្រមូលពន្ធអាចអោយអ្នកជំពាក់ ពន្ធពិតប្រាកដដែលជាអ្នកបំរើការងារនោះបង់ប្រាក់ពន្ធ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

គាត ឈន់

* * *

ប្រកាស

ស្តីពី

ពន្ធលើប្រាក់បៀវត្ស

ជំពូកទី ១

ដែនអនុវត្តន៍នៃពន្ធ

ផ្នែកទី ១ . បុគ្គលជាប់ពន្ធ

១. អ្នកបំរើការងារសហគ្រាសសាធារណៈ

២. អ្នកបំរើការងារសហគ្រាសឯកជន

៣. អ្នកបំរើការងារសហគ្រាសចំរុះ

ផ្នែកទី ២ . បុគ្គលដែលត្រូវបានលើកលែងពន្ធ

កំណត់សំគាល់ :

ជំពូកទី ២

មូលដ្ឋានកំណត់ពន្ធ

ផ្នែកទី ១ . គោលការណ៍ទូទៅ

កំណត់សំគាល់ :

ផ្នែកទី ២ . ចំណែកនៃលាភការជាប់ពន្ធ

(មាត្រា ១៥ នៃច្បាប់)

១. ប្រាក់បៀវត្សពិត
២. ចំណែកបន្ទាប់បន្សំដែលបានទទួលជាសាច់ប្រាក់
២,១. បុព្វលាភ ប្រាក់ម៉ោងបន្ថែម
២,២. ប្រាក់បំណាច់
២,៣. ចំណែកបន្ទាប់បន្សំផ្សេងៗទៀតគ្រប់ប្រភេទ
៣. អត្ថប្រយោជន៍ជាវត្ថុ
៣,១. បែបបទនៃការវាយតំលៃអត្ថប្រយោជន៍ជាវត្ថុ
៣,២. អត្ថប្រយោជន៍ជាវត្ថុ ដែលបានផ្តល់អោយដោយនិយោជកត្រូវបានវាយតំលៃដូចតទៅ :

ផ្នែកទី ៣ . ចំណែកនៃលាភការដែលត្រូវបានលើកលែងពន្ធ

១. ប្រាក់បំណាច់ដែលពុំមានលក្ខណៈជាប្រាក់បៀវត្សបន្ថែម
២. ករណីពិសេសនៃប្រាក់បំណាច់ពីការបញ្ឈប់លែងអោយធ្វើការ
៣. ប្រាក់សងដោយពិតប្រាកដនូវសោហ៊ុយវិជ្ជាជីវៈ
៤. លាភការបំពេញបន្ថែមមានលក្ខណៈជាសង្គមកិច្ច
៥. ការផ្គត់ផ្គង់ដោយឥតគិតថ្លៃឬយកថ្លៃទាបជាងថ្លៃដើមនូវឯកសណ្ឋាន និងបរិក្ខាវិជ្ជាជីវៈពិសេស

ផ្នែកទី ៤ . ការកំណត់មូលដ្ឋានគិតពន្ធ

១. ការកំណត់មូលដ្ឋានដុលសំរាប់គិតពន្ធ
១,១. ចំនួនសរុបដែលបានបង្កើតឡើងដោយ
១,២.
២. ការបន្ថយមូលដ្ឋានកំណត់ពន្ធសំរាប់កូនជាអនីតិជននៅក្នុងបន្ទុក

ជំពូកទី ៣

ដែនដីនៃពន្ធ

ផ្នែកទី ១ . សកម្មភាពបំរើការងារនៅកម្ពុជា

ផ្នែកទី ២ . សកម្មភាពបំរើការងារនៅក្រៅកម្ពុជា

ជំពូកទី ៤

ការគណនាប្រាក់ពន្ធ

ផ្នែកទី ១ . តារាងអត្រាពន្ធ គឺជាតារាងអត្រាពន្ធប្រចាំខែ

ផ្នែកទី ២ . តារាងអត្រាពន្ធ គឺជាតារាងអត្រាពន្ធកំណើន

ផ្នែកទី ៣ . រូបមន្តសំរាប់ធ្វើអោយមានការងាយស្រួលនូវតារាងអត្រាពន្ធ

ជំពូកទី ៥

ហេតុបណ្តាលអោយជាប់ពន្ធ

ជំពូកទី ៦

កាតព្វកិច្ចរបស់និយោជក

ផ្នែកទី ១ . ការកាន់បញ្ជីប្រចាំខែដែលមានចុះចំនួនប្រាក់ បានបើក និង ចំនួនប្រាក់បានកាត់ទុក

ផ្នែកទី ២ . ការបង់ប្រាក់ប្រចាំខែនូវប្រាក់ពន្ធលើប្រាក់បៀវត្សរ៍ដែលបានកាត់ទុក

ផ្នែកទី ៣ . ការលើកលែងនូវគោលការណ៍នៃការបង់ប្រាក់ពន្ធប្រចាំខែ

១. ការកំណត់មូលដ្ឋានគិតពន្ធនៅកម្ពុជា

២. ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សដែលត្រូវបង់នៅកម្ពុជាមុនពេលកាត់ឥណទានពន្ធ

៣. ការកំណត់ឥណទានពន្ធ

៤. ការកំណត់ប្រាក់ពន្ធលើប្រាក់បៀវត្សកម្ពុជា

កំណត់សំគាល់ :

ផ្នែកទី ៤ . ការដាក់លិខិតប្រកាសសារពើពន្ធ

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១៧៨ ប្រក.សហវ.ថ

ស្តីអំពីការបង្វែរឥណទាន

* * *

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋា ភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយ ប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ ស្តីអំពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពី ការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាម ឥណទាន ចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ លេខ ១៩៨១ ហក. កបទ ចុះថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៥

សំរេច

ប្រការ១ : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

ជំពូក	ប្រការ	កថាខ័ណ្ឌ	វាក្យខ័ណ្ឌ	ចំណាត់ថ្នាក់ចំណាយ	ស្ថានភាពឥណទានដើមឆ្នាំ	ការកែប្រែឥណទាន		ស្ថានភាពឥណទានថ្មី
						កើន	ថយ	
១១	០១	៦៦	-	ការបង្វែរពីជំពូក១១ ចំណាយផ្សេងៗលើការប្រើប្រាស់ទ្រព្យសម្បត្តិនិងសេវាកម្មនានា	១.១៧៨.០០០		៤០០.០០០ ៤០០.០០០	៧៧៨.០០០
១១	០១	០២	-	ផលប្រយោជន៍ជំពូក១១ ចលនវត្ថុ និងសំភារៈ		៤០០.០០០ ៤០០.០០០		៤០០.០០០

ប្រការ ២ : ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអ្នកទទួលបន្ទុកក្នុងការ អនុវត្តប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ហត្ថលេខានិងត្រា

គាត ឈន់

* * *

២-ទីស្តីការរដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ៤០៨ ឧកប្រក ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ែន ម៉េង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៣៩០១៥ ត.ក ចុះថ្ងៃទី ១៥-១២-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិរុន ឃុំចំបក់ ស្រុកបាទី ខេត្ត តាកែវ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣១សេះ នៅក្នុងទីតាំង ភូមិត្រាំខ្នារ ឃុំស្លូភី ស្រុកបាទី ខេត្តតាកែវ ។

ប្រការ ២ : លោក **ម៉ែន ម៉េង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែល

បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូត វិញ ដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤០៩ ឧក.ប្រក ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ម៉ែន ម៉េង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ០៣៥០១៥ ត.ក ចុះថ្ងៃទី ១៥-១២-៨៧ អាស័យដ្ឋានបច្ចុប្បន្ន ភូមិរុន ឃុំចំបក់ ស្រុកបាទី ខេត្ត តាកែវ បើកដំណើរការរោងម៉ាស៊ីនកិនស្រូវ កំលាំង ៣១សេះ នៅក្នុងទីតាំង ភូមិភ្នំតូច ឃុំស្លូភី ស្រុកបាទី ខេត្តតាកែវ ។

ប្រការ ២ : លោក **ម៉ែន ម៉េង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំងដែល បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវ ធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើស ច្បាប់ ឬបង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយ គ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤១៥ ឧក.ប្រក ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយលោក **ឈាន ឈេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្ត សញ្ញាណប័ណ្ណលេខ ០៧៣៩៤៦ ព.ស ចុះថ្ងៃទី ០៥-០២-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៧ ភូមិអូរតាប៉ោង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិសាត់ បើកដំណើរ ការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ឈាន ឈេង** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្មលើទីតាំងដែល

បានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាង តិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយះពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៤១៦ ផក.ប្រក ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក **ចាម ចាន់ឡាយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្ត សញ្ញាណប័ណ្ណ លេខ ១២៥២៣៧ ព.ស ចុះថ្ងៃទី ០៨-៧-៩៤ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី៥ ភូមិរលេច ឃុំរលេច ស្រុកបាកាន ខេត្តពោធិសាត់ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១២០សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក **ចាម ចាន់ឡាយ** ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម-អាជីវកម្ម លើទីតាំង ដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតម្លៃក្នុងរយះពេល បីឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋាន ត្រូវធ្វើពាក្យ សុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្ត ល្មើសច្បាប់ ប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ពូ សុធីរៈ

* * *

៣-និស្ថិការរដ្ឋមន្ត្រី ក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៤៤ ពម.ប្រក

ស្តីពីការអនុញ្ញាតអោយបើកអាជីវកម្មរោងពុម្ពឈ្មោះ ដំបងដែក

* * *

រដ្ឋមន្ត្រី ក្រសួង ពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាបាទ សម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- យោងលិខិតជូនដំណឹង របស់ក្រសួងពត៌មាន លេខ ១.២២៤ -៩៤ ព.ម ចុះថ្ងៃទី ១៨-១១-៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ « **ដំបងដែក** » របស់លោក **គួច សាខន** ចុះថ្ងៃទី ២៨_៥_៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយលោក **គួច សាខន** ស្ថិតនៅផ្ទះលេខ ០៥ ផ្លូវលេខ ៣០២ ក្រុមទី ៥០ សង្កាត់ បឹងកេងកង ១ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ បើកអាជីវកម្មរោងពុម្ពឈ្មោះ «ដំបងដែក» ស្ថិតនៅផ្ទះលេខ ៦៤៨ ក្រុមទី ២២ សង្កាត់ចាក់អង្រែក្រោមស្រុកមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២: រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅនឹងទំនៀមទំលាប់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើសដូចមានចែងក្នុងប្រការ ២ សាមីខ្លួននឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងបោះពុម្ពផ្សាយ សោតទស្សន៍ នៃអគ្គនាយកដ្ឋាន រដ្ឋបាល និង

ហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

ប្រការ ៥ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខានិងត្រា

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១៥/៩៥ ពម.ប្រ.ក

ស្តីពីការលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌក្រសួង

* * *

រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥
- បានឃើញសេចក្តីសំរេចលេខ ៨៩ ស.រ ចុះថ្ងៃទី ១០-១០-៩៣ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីប្រព័ន្ធបៀវត្សកម្មាភិបាល បុគ្គលិក កម្មករ រដ្ឋ
- បានឃើញសារាចរលេខ ០១ ស.រ ចុះថ្ងៃទី ២៨-០១-៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការរាប់មន្ត្រីរាជការទូទាំងព្រះរាជាណាចក្រកម្ពុជា
- យោងតាមរបាយការណ៍ របស់អគ្គនាយកដ្ឋានកាសែតកម្ពុជា លេខ ២៣ ក.ស.ក.ប.ល ចុះថ្ងៃទី ០៨-២-៩៥ ។

សំរេច

ប្រការ ១ : លុបឈ្មោះលោក **ខេត សុជាតា** អ្នកកាសែតថ្នាក់ឧត្តម ចេញពីក្របខ័ណ្ឌរបស់អគ្គនាយកដ្ឋានកាសែតកម្ពុជា នៃក្រសួងពត៌មាន ។

ប្រការ ២ : ប្រាក់បៀវត្ស និង [illegible]ត្ថម្ភផ្សេងៗ របស់សាមីខ្លួន ត្រូវផ្តាច់ចេញពីតារាងបើកប្រាក់បៀវត្ស របស់អគ្គន[illegible]កដ្ឋាន កាសែតកម្ពុជា ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥ នេះតទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋានកាសែតកម្ពុជា ,នាយកដ្ឋានរដ្ឋបាល បុគ្គលិក ,នាយកដ្ឋានគណនេយ្យ ផែនការ ហិរញ្ញវត្ថុ និង សាម៉ីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាស លេខ ១១៥/៩៥ ព.ម.ប្រក

ស្តីពីការលុបឈ្មោះ មន្ត្រីរាជការ

* * *

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីសំរេច របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី លេខ ២៤៥ សសរ ចុះថ្ងៃទី ០៥-១១-៨៨ ស្តីពីរបបគោលនយោបាយរ៉ាប់រងសង្គម សំរាប់កម្មាភិបាល បុគ្គលិក កម្មកររដ្ឋ និវត្តជន និង ជនបាត់បង់សមត្ថភាពពលកម្ម ។
- យោងសារាចរណែនាំ លេខ ០២ សកអ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ស្តីពីការអនុវត្តន៍គោលនយោបាយសោធនជានារ៉ាប់រង សង្គម និងសង្គ្រោះសង្គម ។
- បានឃើញលិខិត លេខ ៤៣ ឃព.ក្រច ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ១៩៩៥ របស់ប្រធានមន្ទីរពត៌មាន ខេត្តក្រចេះ ស្តីពីសំណើសុំលុបឈ្មោះមន្ត្រីរាជការ ។

សំរេច

ប្រការ ១ : លុបឈ្មោះអ្នកស្រី **ជុំ សុទី** បុគ្គលិកការិយាល័យ ពត៌មាននៃមន្ទីរពត៌មាន ខេត្តក្រចេះ ចាប់ពីថ្ងៃទី ០១-១០-៩៥ តទៅ :

មូលហេតុ : មរណភាពក្នុងពេលធ្វើការ ។

ប្រការ ២ : គ្រួសារសពត្រូវបានទទួលជំនួយឧបត្ថម្ភដូចតទៅ :

ក–ជំនួយបុណ្យសព	១.៨០០៛ × ៦	=	១០.៨០០៛០០
ខ–ប្រាក់បៀវត្ស ឥ II .២	២៦.៤០០៛ × ៦	=	១៥៨.៤០០៛០០
គ–ប្រាក់បន្ថែម ៣០%	៧.៨០០៛ × ៦	=	៤៦.៨០០៛០០
ឃ–ប្រាក់គំរូន	១.៥០០៛ × ៦	=	៩.០០០៛០០
	សរុប	=	២២៥.០០០៛០០

(ពីររយម្ភៃប្រាំពាន់រៀលគត់)

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ មន្ទីរពត៌មានខេត្ត ក្រចេះ និង សាមីជន ពាក់ព័ន្ធ មានភារៈអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១៧/៩៥ ព.ម

ស្តីពីការអនុញ្ញាតអោយកាសែតឈ្មោះ

(LE QUOTIDIE DU CAMBODGE)

ចេញផ្សាយជាភាសាខ្មែរ – បារាំង

* * *

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានប្បញ្ញត្តិមាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់សារពត៌មានត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៩៩២ និតិកាលទី១ ។
- បានឃើញ លិខិតស្នើសុំផ្លាស់ប្តូរចាងហ្វាងសារពត៌មាន (LE QUOTIDIE DU CAMBODGE) ចុះថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៥ ។

សម្រេច

ប្រការ ១ : អនុញ្ញាតអោយកាសែតឈ្មោះ (LE QUOTIDIE DU CAMGODGE) ចេញផ្សាយ ជាភាសា ខ្មែរ–បារាំង ដោយមានលោក **ម៉ែនសាម៉ាត** ជាចាងហ្វាងការផ្សាយ ។

ប្រការ ២ : ខ្លឹមសារអត្ថបទ និងសកម្មភាពផ្សព្វផ្សាយត្រូវស្រប តាមទំនៀមទំលាប់ប្រពៃណីល្អ និង ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : គោរពច្បាប់សារពត៌មាន តាមគោលការណ៍ក្រមសីលធម៌អ្នកកាសែត និង ឈរលើស្មារតី ទទួលខុសត្រូវខ្ពស់លើវិជ្ជាជីវៈរបស់ខ្លួន និងស្នើប្រគល់កាសែតចំនួន ១៥ ច្បាប់រៀងរាល់លេខចេញ ផ្សាយមកតំកល់ទុកជាឯកសារនៅក្រសួងពត៌មាន ។

ប្រការ ៤ : លោក **ម៉ែន សាម៉ាត** ចាងហ្វាងការផ្សាយកាសែត (LE QUOTIDIE DU CAMBODGE) និង នាយកដ្ឋានមណ្ឌលពត៌មាន នៃក្រសួងពត៌មានត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៥ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

អៀង មូលី

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១៨/៩៥ ពម.ប្រក

ស្តីពីការអនុញ្ញាតអោយបើកការិយាល័យ

តំណាងផ្សព្វផ្សាយពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជំពូកអវសានបញ្ញត្តិ មាត្រាទី ១៣៩
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១–១១–១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់សារពត៌មានត្រូវបានរដ្ឋសភា នៃរដ្ឋកម្ពុជាអនុម័តនាសម័យប្រជុំវិសាមញ្ញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ១៩៩២ នីតិកាលទី ១ ។

- បានឃើញ លិខិតស្នើសុំអនុញ្ញាតបើកការិយាល័យ តំណាងផ្សព្វផ្សាយពាណិជ្ជកម្មនៅកម្ពុជា PRAKIT/FCB ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតជូនលោក **ស៊ិរិ គិចសុវណ្ណ** «SIRI KIJSUWAN» សញ្ជាតិថៃ បើកការិយាល័យ តំណាងផ្សព្វផ្សាយពាណិជ្ជកម្ម PRAKIT/FCB ដែលមានរូបលោកផ្ទាល់ជាអ្នកទទួលខុសត្រូវ ។

ប្រការ ២ : ខ្លឹមសារនិងសកម្មភាពផ្សព្វផ្សាយត្រូវសមស្របតាមទំនៀមទំលាប់ ប្រពៃណីល្អ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដោយសហការជាមួយនាយកដ្ឋានមណ្ឌលពត៌មាន ។

ប្រការ ៣ : លោក **ស៊ិរិ គិតសុវណ្ណ** អ្នកគ្រប់គ្រងការិយាល័យតំណាងផ្សព្វផ្សាយពាណិជ្ជកម្ម PRAKIT/FCB និង នាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មានត្រូវអនុវត្តន៍នូវប្រកាសនេះ ។

ប្រការ ៤ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

អៀង មូលី

* * *

៤-ឧិស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១២ ប្រក.វទស.ប

ស្តីពីការបង្កើតគណៈកម្មការនិងអនុគណៈកម្មការ

រៀបចំកម្មវិធីសិក្សាសិល្បៈជាមួយក្រសួងអប់រំ

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- តាមសេចក្តីត្រូវការចាំបាច់របស់ក្រសួង

សំរេច

មាត្រា ១ : ត្រូវបានបង្កើតគណៈកម្មការអចិន្ត្រៃយ៍ និងអនុគណៈកម្មការមួយ សំរាប់រៀបចំកម្មវិធីសិក្សា សិល្បៈជាមួយក្រសួងអប់រំដែលមានសមាសភាពដូចតទៅ ÷

គណៈកម្មការអចិន្ត្រៃយ៍

១-លោក **ឃួន ថន**	អគ្គនាយករងបច្ចេកទេស	ប្រធាន
២-លោក **នុយ គឿន**	ប្រតិភូ ស.រ.ស	សមាជិក
៣-លោក **ហង្ស សុត**	ប្រធាននាយកដ្ឋានសិល្បៈ	សមាជិក

អនុគណៈកម្មការទទួលបន្ទុកផ្នែករបាំ :

១-លោកស្រី **ឃួន ណារី**		ប្រធាន
២-លោកស្រី **លួន សុខាំ**		សមាជិក
៣-លោកស្រី **ហ៊ឹម ណាឡា**		សមាជិក

អនុគណៈកម្មការទទួលបន្ទុករៀបចំកម្មវិធីសិក្សា
ផ្នែកភ្លេង និងចំរៀង

១-លោក **ហ៊ុន សារិន**	សាស្ត្រាចារ្យជួបតន្ត្រី	ប្រធាន
២-លោក **ម៉ៅ គឿន**	សាស្ត្រាចារ្យជួបតន្ត្រី	សមាជិក
៣-លោក **យន់ ខៀន**	សាស្ត្រាចារ្យជួបតន្ត្រី	សមាជិក

អនុគណៈកម្មការទទួលបន្ទុកផ្នែកគំនូរ

១-លោក **អ៊ុច មិញស៊ិញ**	សាស្ត្រាចារ្យវិចិត្រកម្ម	ប្រធាន
២-លោក **ទៀង សុផន**	សាស្ត្រាចារ្យវិចិត្រកម្ម	សមាជិក
៣-លោក **ចាប សួន**	សាស្ត្រាចារ្យវិចិត្រកម្ម	សមាជិក

ប្រការ ២ : ប្រធានគណៈកម្មការអចិន្ត្រៃយ៍ មានសិទ្ធិកោះប្រជុំសមាជិក និង បណ្តាអនុគណៈ

កម្មការទាំងបី និងអង្គភាពដែលពាក់ព័ន្ធដើម្បីរៀបចំ វិធីសាស្ត្រការងារអោយមានប្រសិទ្ធភាព ។

មាត្រា ៣ : អគ្គនាយកដ្ឋានបច្ចេកទេស–អគ្គនាយកដ្ឋានរដ្ឋបាល–សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ នាយកដ្ឋានសិល្បៈ ព្រមទាំងសាមីខ្លួនមានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និងត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ម៉ាណារ៉ា

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១១៤ ប្រក.វវស.បុ

ស្តីពីការលុបឈ្មោះមន្ត្រីរាជការ

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញពាក្យសុំលាលប់ពីការងាររបស់លោក **សេង ម៉ី** ។

សំរេច

មាត្រា ១ : លោក **សេង ម៉ី** បុគ្គលិកនាយកដ្ឋានអភិវឌ្ឍវប្បធម៌ត្រូវបានអនុញ្ញាតអោយលុបឈ្មោះចេញ ពីបញ្ជីក្របខ័ណ្ឌបុគ្គលិកក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចាប់ពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ១៩៩៥ ដោយ សុំលាឈប់ ។

មាត្រា ២ : អគ្គនាយកដ្ឋានបច្ចេកទេស អគ្គនាយកដ្ឋានរដ្ឋបាល នាយកដ្ឋានអភិវឌ្ឍវប្បធម៌ និងលោក **សេង ម៉ី** មានភារកិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និងត្រា

ស៊ីសុវត្ថិ ស៊ីរីវុធ ម៉ាណារ៉ា

៥-ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាស លេខ ៦៤៥ អយក.ប្រក

ស្តីពីការកំនត់មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២

* * *

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញក្រឹត្យ–ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ
- បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២២៣៧ សជណ.អវ ចុះថ្ងៃទី ១៩ វិច្ឆិកា ១៩៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំនេះទូទៅ ។
- បានឃើញប្រកាសក្រសួងលេខ ២៣២៩ អវ.ចខម ចុះថ្ងៃទី ១៧ ឧសភា ១៩៨០ ស្តីពីការបង្កើតអោយមានការប្រលងសញ្ញាប័ត្រកំរិតសិក្សាទី៣ ។
- បានឃើញប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាលេខ ៦៤៤ អយក.ប្រក ចុះថ្ងៃទី ៣១ ខែ ឧសភា ១៩៩៥ ស្តីពីការរៀបចំប្រព្រឹត្តិទៅនៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត២ ។
- យោងសំណើរបស់មន្ទីរអប់រំយុវជន និង កីឡា ខេត្ត–ក្រុង ស្តីពីការសុំបើកមណ្ឌលប្រលងសញ្ញាប័ត្រ មធ្យមសិក្សាកំរិត២ តាមខេត្ត–ក្រុង ។

សំរេច

ប្រការ ១ : មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ចំណេះទូទៅនិងបំពេញវិជ្ជាលើកទី១ សម័យប្រលង ២៧ មិថុនា ១៩៩៥ ត្រូវកំណត់ដូចតទៅ ÷

I-រាជធានីភ្នំពេញមាន ០៦ មណ្ឌល:

១–មណ្ឌលវិទ្យាល័យបាក់ទូកមាន ៣៥ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៣ បន្ទប់
២–មណ្ឌលវិទ្យាល័យសន្ធរម៉ុកមាន ៣៥ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៣ បន្ទប់
៣–មណ្ឌលវិទ្យាល័យទួលទំពូងមាន ៣៥ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៣ បន្ទប់
៤–មណ្ឌលវិទ្យាល័យបឹងត្របែកមាន ៣៥ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៣ បន្ទប់
៥–មណ្ឌលវិទ្យាល័យព្រះស៊ីសុវត្ថិមាន ៣៥ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៣ បន្ទប់
៦–មណ្ឌលអនុវិទ្យាល័យចតុមុខមាន ៣២ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៥ បន្ទប់

II-ខេត្តកំពង់ចាមមាន ០៣ មណ្ឌល:

១–មណ្ឌលវិទ្យាល័យព្រះសីហនុមាន ៥៩ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៦ បន្ទប់
២–មណ្ឌលវិទ្យាល័យព្រៃឈរមាន ២៣ បន្ទប់
៣–មណ្ឌលបឋមទួលថ្មមាន ១៥ បន្ទប់

III-ខេត្តកណ្តាល មាន ០៤ មណ្ឌល និង ០១ អនុមណ្ឌល:

១–មណ្ឌលវិទ្យាល័យជ័យវរ្ម័នទី៧មាន ២៩ បន្ទប់
២–មណ្ឌលអនុវិទ្យាល័យព្រះសីហនុវរ្ម័ន «ស្អាង» មាន ២១ បន្ទប់
៣–មណ្ឌលវិទ្យាល័យទេពប្រណម្យមាន ២១ បន្ទប់
៤–មណ្ឌលវិទ្យាល័យតាខ្មៅមាន ២០ បន្ទប់
–អនុមណ្ឌលបឋមតាខ្មៅមាន ១២ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៣ បន្ទប់

IV-ខេត្តបាត់ដំបង មាន ០២ មណ្ឌល និង ០២ អនុមណ្ឌល :

១–មណ្ឌលវិទ្យាល័យបាត់ដំបងមាន ៤០ បន្ទប់
–អនុមណ្ឌលអនុវិទ្យាល័យទីរួមខេត្តមាន ១១ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ១១ បន្ទប់
២–មណ្ឌលវិទ្យាល័យស្វាយប៉ោមាន ២៨ បន្ទប់
–អនុមណ្ឌលបឋមសម្តេច ជា ស៊ីមមាន ១០ បន្ទប់

V-ខេត្ត ព្រៃវែង មាន ០៣ មណ្ឌល់ :

១–មណ្ឌលវិទ្យាល័យ ព្រះអង្គឌួង មាន ២៧ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០២ បន្ទប់
២–មណ្ឌលវិទ្យាល័យកំពង់ត្របែកមាន ១៧ បន្ទប់
៣–មណ្ឌលវិទ្យាល័យស្វាយអន្ទរ មាន ១៤ បន្ទប់

VI-ខេត្តតាកែវ មាន ០២ មណ្ឌល :

១-មណ្ឌលវិទ្យាល័យតាកែវ មាន ៣០ បន្ទប់

២-មណ្ឌលគរុកោសល្យ ភូមិភាគ មាន ២១ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១ បន្ទប់

VII-ខេត្តស្វាយរៀង មាន ០១ មណ្ឌល :

១-មណ្ឌលវិទ្យាល័យស្វាយរៀង មាន ៤៣ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១ បន្ទប់

VIII-ខេត្តកំពត មាន ០២ មណ្ឌល :

១-មណ្ឌលវិទ្យាល័យព្រះរាជសម្ភារ មាន ២៧ បន្ទប់

២-មណ្ឌលបឋមកំពតក្រុង មាន ១១ បន្ទប់

IX-ខេត្ត សៀមរាប មាន ០១ មណ្ឌល និង ១ អនុមណ្ឌល :

១-មណ្ឌលអនុវិទ្យាល័យអង្គរ មាន ២៤ បន្ទប់

-អនុមណ្ឌលវិទ្យាល័យ ១០មករា មាន ១០ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០៥ បន្ទប់

X-ខេត្តកំពង់ធំ មាន ០១ មណ្ឌល :

១-មណ្ឌលវិទ្យាល័យកំពង់ធំមាន ៣១ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១ បន្ទប់

XI-ខេត្តបន្ទាយមានជ័យ មាន ០១ មណ្ឌល :

១-មណ្ឌលវិទ្យាល័យបន្ទាយមានជ័យ មាន ២៦ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០២ បន្ទប់

XII-ខេត្ត ក្រចេះមាន ០១ មណ្ឌល :

១-មណ្ឌលវិទ្យាល័យព្រះមហាក្សត្រិយានីកុសុម : មាន ២៥ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១ បន្ទប់

XIII-ខេត្តកំពង់ស្ពឺ មាន ០២ មណ្ឌល :

១-មណ្ឌលវិទ្យាល័យកំពង់ស្ពឺ មាន ១៤ បន្ទប់

២-មណ្ឌលវិទ្យាល័យ សុខាផល្លី មាន ១០ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១ បន្ទប់

XIV-ខេត្តកំពង់ឆ្នាំង មាន ០១ មណ្ឌល :

១-មណ្ឌលវិទ្យាល័យព្រះបាទសុរាម្រឹតមាន ១៧ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០២ បន្ទប់

XV-ខេត្ត ពោធិសាត់ មាន ០១ មណ្ឌល :

១–មណ្ឌលវិទ្យាល័យពោធិសាត់ មាន ១៥ បន្ទប់ ក្នុងនោះបំពេញវិជ្ជា ០១ បន្ទប់

XVI-ក្រុងព្រះសីហនុមាន ០១ មណ្ឌល :

១–មណ្ឌលអនុវិទ្យាល័យសម្តេចឪ មាន ០៨ បន្ទប់

XVII-ខេត្ត ព្រះវិហារ មាន ០១ មណ្ឌល :

១–មណ្ឌលវិទ្យាល័យត្បែងមានជ័យមាន ០២ បន្ទប់

XVIII-ខេត្ត កោះកុង មាន ០១ មណ្ឌល :

១–មណ្ឌលវិទ្យាល័យកោះកុង ០២ បន្ទប់

XIX-ខេត្តស្ទឹងត្រែង មាន ០១មណ្ឌល:

១–មណ្ឌលវិទ្យាល័យព្រះរាជបូទីយកិច្ចមាន ០២ បន្ទប់

ប្រការ ២ : ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្ត–ក្រុង និងនាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានសិក្សារបស់ខ្លួន ត្រូវយកធ្វើជាមណ្ឌលប្រលងមានភារកិច្ចរៀបចំមណ្ឌលប្រលងសៀវភៅកំរងរូបថត បេក្ខជន បញ្ជីផ្សេងៗ និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តិទៅនៃការប្រលងអោយហើយស្រេចមុនបើកសម័យប្រលង ។

ប្រការ ៣ : ប្រធាននាយដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានអប់រំមនុស្សចាស់ ប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានមន្ទីរក្រសួងអប់រំ យុវជន និង កីឡា ត្រូវអនុវត្តតាមភារកិច្ចរៀងៗខ្លួន ដើម្បីអោយបានសំរេចតាមប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សោភាន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៦៥៣ អយក.ប្រក

ស្តីពីការបើកសាលារៀនកុមារពិការភ្នែក

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជា ព្រះចៅក្រុងកម្ពុជា ធិបតី ចុះថ្ងៃទី ១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-១៩៩៤
- បានឃើញក្រឹត្យច្បាប់ លេខ ៣០ ក្រច ចុះថ្ងៃទី ២០-១១-១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានពិនិត្យកិច្ចព្រមព្រៀងរវាងក្រសួងអប់រំ នៃរដ្ឋកម្ពុជា និងអង្គការគ្រួសារថ្មី ចុះថ្ងៃទី ១៨-៥- ១៩៩៣.
- បានឃើញលិខិតស្នើសុំរបស់អង្គការគ្រួសារថ្មីលេខ ១២-៩៤ ចុះថ្ងៃទី ១២-១២-៩៤
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា

សំរេច

ប្រការ ១ : អនុញ្ញាតអោយបើកសាលារៀនកុមារពិការភ្នែក ច្បារអំពៅ ដែលមានទីតាំងនៅ ភូមិច្បារអំពៅ ស្រុកមានជ័យ រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ១៩៩៤-៩៥ នេះតទៅ ។

ប្រការ ២ : សាលានេះស្ថិតនៅក្រោមគ្រប់គ្រងរបស់អង្គការគ្រួសារថ្មី ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ស្របតាមកិច្ចព្រមព្រៀងរវាងក្រសួងអប់រំ នៃរដ្ឋកម្ពុជា និង គ្រួសារថ្មី ចុះថ្ងៃទី ១៨ ឧសភា ឆ្នាំ ១៩៩៣ ។

ប្រការ ៣ : សាលារៀនកុមាពិការភ្នែកច្បារអំពៅ ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការ ចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមតំរូវការរបស់សាលា និង តាមការចាត់តាំងរបស់ អង្គការគ្រួសារថ្មី ។

ប្រការ ៤ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀត របស់នាយក នាយករង បុគ្គលិកសិក្សា ធុសិស្ស និង រាល់ការចំណាយទាំងអស់ ក្នុងដំណើរការសាលា ជាបន្ទុករបស់អង្គការ គ្រួសារថ្មី ។

ប្រការ ៥ : មន្ទីរនាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា នាយកដ្ឋានចាត់តាំង នាយកដ្ឋាន ផែនការ និងហិរញ្ញវត្ថុ នៃក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ចរៀងៗខ្លួនអនុវត្ត សេចក្តីប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

គា សាឃាន

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ មិថុនា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៦៥៤ អយក.ប្រក

ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃការ

ប្រលងសញ្ញាប័ត្រមធ្យម សិក្សាភូមិ១

រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ថ្វាយ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ ១០៩៤.៩០ ន.ស.រ.ក.ត ចុះថ្ងៃទី ៣១-១០-៩៤ ស្តីពី ការកែសម្រួល សមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៧-៩៤
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធ អប់រំចំណេះ ទូទៅ ។
- បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២២៣៧ សជណ.អវ ចុះថ្ងៃទី ១៩ វិច្ឆិកា ១៩៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ ។

- បានឃើញប្រកាសក្រសួង ២៣២៩ ចុះថ្ងៃទី ១៧ ឧសភា ១៩៨០ ស្តីពីការបង្កើតអោយមានការ ប្រលងសញ្ញាប័ត្រកំរិតសិក្សាទី២ ។
- បានឃើញសេចក្តីសំរេចលេខ ៤៥ អយក.ចទម ចុះថ្ងៃទី ១២ ឧសភា ១៩៩៤ ស្តីពីការរៀបចំប្រលង សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ និងអត្ថបទកែប្រែជាបន្តបន្ទាប់ ។

សំរេច

ប្រការ ១ : មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ លើកទី ១ និងលើកទី ២ ត្រូវកំនត់ដោយក្រសួង អប់រំយុវជន និងកីឡា រៀងរាល់ឆ្នាំសិក្សាដោយផ្អែកលើសំណើរបស់ប្រធានមន្ទីរអប់រំយុវជននិងកីឡា ខេត្ត–ក្រុង ។

ប្រការ ២ : ប្រធានមន្ទីរអប់រំយុវជន និងកីឡា ខេត្ត–ក្រុង និងនាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានសិក្សាត្រូវបានកំណត់ជាមណ្ឌលប្រលង ត្រូវរៀបចំបន្ទប់ប្រលង សៀវភៅរូបថតបេក្ខជន បញ្ជីផ្សេងៗ និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តិទៅ នៃការប្រលងអោយហើយស្រេចមុនបើកសម័យប្រលង ។ ចំពោះសាលាក្រោមនិវាទផ្ទាល់នៃក្រសួងអប់រំយុវជន និងកីឡា នាយកគ្រឹះស្ថានមធ្យមសិក្សា ក៏ត្រូវ អនុវត្តដូចមណ្ឌលនានាដែរ តាមការណែនាំរបស់នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ។

ប្រការ ៣ : នឹងអាចសុំចុះឈ្មោះប្រលងលើកទី ១ បាន បេក្ខជនទាំងឡាយណាជាសិស្សថ្នាក់ទី ៨ នៃគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ និងឯកជនដែលបានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី ៨ ។ ពាក្យសុំចុះឈ្មោះ ប្រលងមានបិទតែមប្រ៊ី ត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាតាមរយៈឋានានុក្រម ។

ប្រការ ៤ : នឹងអាចអនុញ្ញាតអោយចូលរួមប្រលងលើកទីពីរបាន ៖

- បេក្ខជនដែលបានប្រលងធ្លាក់លើកទីមួយ និងបានពិន្ទុសរុបនៃការប្រលងលើកទីមួយ ចាប់ពី ៣/៥ នៃពិន្ទុ ៣០ (គឺពិន្ទុចាប់ពី ១៨)ឡើងទៅ ។
- បេក្ខជនដែលបានដាក់ពាក្យសុំប្រលងលើកទីមួយ តែអាក់ខានពុំបានចូលរួមប្រលង ឬបានចូលរួម ប្រលងពុំបានគ្រប់មុខវិជ្ជាដោយមូលហេតុមានជម្ងឺ ឬគ្រោះថ្នាក់ផ្សេងៗ ដាក់ស្តែងដែលមានលិខិត បញ្ជាក់ច្បាស់ពីគ្រូពេទ្យ និងអាជ្ញាធរមានសមត្ថកិច្ច ។

ប្រការ ៥ : អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ ជាបេក្ខជនស្វ័យរិនបាន អតីតបេក្ខជនដែលប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត១ ។

ប្រការ ៦ : បេក្ខជនត្រូវភ្ជាប់នឹងពាក្យសុំប្រលងរបស់ខ្លួននូវ :

- សាលាកប័ត្រឯកត្តជនទំហំ ១៥សម × ២១សម មានបិទរូបថតថ្មី ថតចំពីមុខ ទំហំ ៤សម × ៦សម ចំនួន ០៦ សន្លឹក
- បង្កាន់ដៃបង់សិទ្ធិប្រលង ០១ ច្បាប់
- រូបថតថ្មី ថតចំពីមុខ ទំហំ ៤សម × ៦សម «រូបថតដែលបានបិទលើសលាកប័ត្រ» ចំនួន ០៥សន្លឹក
- សៀវភៅសិក្សាគារិក « ចំពោះសិស្សសាលាឯកជន »

ប្រការ ៧ : ពាក្យសុំចុះឈ្មោះប្រលងលើកទីមួយ និង លើកទីពីរ នឹងត្រូវប្រមូលផ្តុំតាមគ្រឹះស្ថានសិក្សាដែលខ្លួនសិក្សា ។ នាយកគ្រឹះស្ថានសិក្សាត្រូវប្រមូលសំណុំលិខិតរបស់បេក្ខជន និង បញ្ជីរាយនាមបេក្ខជន តាមលំដាប់អក្សរបញ្ជូនទៅមណ្ឌលប្រលងតាមរយៈឋានានុក្រម និងតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

ប្រការ ៨ : បេក្ខជន ដែលបានប្រកាសថាជាប់ជាបេក្ខភាពប្រលងលើកទីពីរ មិនបាច់ដាក់ពាក្យសុំប្រលងទៀតទេ លើកលែងតែបេក្ខជនដែលបានដាក់ពាក្យលើកទីមួយ តែអាក់ខានពុំបានចូលរួមប្រលង ឬ ចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជាដោយមូលហេតុមានជម្ងឺ ឬគ្រោះថ្នាក់ផ្សេងៗជាក់ស្តែង ត្រូវដាក់ពាក្យ សុំប្រលងជាថ្មីនៅមន្ទីរអប់រំយុវជន និង កីឡាខេត្ត–ក្រុង ដែលបេក្ខជនដាក់ពាក្យពីមុន ។

ប្រការ ៩ : បេក្ខជនស្វ័យរិនដែលប្រលងធ្លាក់ពីឆ្នាំមុន ត្រូវបញ្ជាក់លើពាក្យសុំប្រលងនូវសម័យប្រលងមណ្ឌលប្រលងលេខបន្ទប់ លេខតុពីឆ្នាំមុន ហើយត្រូវដាក់ពាក្យសុំប្រលងទៅតាមខេត្តក្រុងដែលសាមី ខ្លួនបានប្រលងពីឆ្នាំមុន ។ បេក្ខជនស្វ័យរិន អតីតសិស្សថ្នាក់ទី ៨ នៃសាលារៀនចំណេះទូទៅដែលបាន ប្តូរលំនៅដ្ឋានទៅខេត្ត–ក្រុងថ្មីហើយមានបំណងចង់ប្រលងនៅខេត្ត–ក្រុងនេះ អាចដាក់ពាក្យសុំ ប្រលងនៅខេត្ត–ក្រុងថ្មីបានក្រោយពីមានសេចក្តីបញ្ជាក់ច្បាស់លាស់ពីមន្ទីរអប់រំខេត្ត–ក្រុងចាស់ ដែលសាមីខ្លួនបានប្រលងធ្លាក់ ។ មន្ទីរអប់រំខេត្ត–ក្រុង ត្រូវធ្វើបញ្ជីរាយនាមបេក្ខជនស្វ័យរិនទាំងអស់ ដោយបញ្ជាក់នូវសម័យប្រលងឆ្នាំមុន មណ្ឌល លេខបន្ទប់ លេខតុរបស់បេក្ខជនផ្ញើទៅក្រសួងអប់រំ «នាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា »

ដើម្បីពិនិត្យ និងសំរេចលើបេក្ខភាព ។

ប្រការ ១០: ការក្លែងបន្លំផ្សេងៗ ពីសំនាក់បេក្ខជនត្រូវទទួលការបញ្ឈប់មិនអនុញ្ញាតអោយប្រលង ចំនួន ពីរឆ្នាំ ។

ប្រការ ១១: មណ្ឌលប្រលងនីមួយៗ ត្រូវមានប្រធាន អនុប្រធានគណៈមេប្រយោគ និង សមាជិកមួយចំនួនតាមការចាំបាច់នៃមណ្ឌលប្រលង ។

ប្រការ ១២: សមាសភាព និង ចំនួនព្រមទាំងលិខិតឧទ្ទេសនាមនៃគណៈមេប្រយោគ ត្រូវសំរេចដោយរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា តាមលិខិតសំណើរបស់ប្រធាននាយកដ្ឋានចំណេះទូទៅ និង មធ្យមសិក្សា ។

ប្រការ ១៣: ចំនួនអនុរក្សនៃមណ្ឌលប្រលង ត្រូវគិតតាមចំនួនបន្ទប់ប្រលងគុណនឹង ២,៥ ។

ប្រការ ១៤: បន្ទប់ប្រលងនីមួយៗ ត្រូវដាក់បេក្ខជនត្រឹមម្ភៃប្រាំ «២៥ » នាក់ ។ បើមានបេក្ខជននៅសល់ពីប្រាំ « ៥ » នាក់ឡើងទៅ ត្រូវដាក់នៅក្នុងបន្ទប់មួយដោយឡែក ។

ប្រការ ១៥: ប្រធានគណៈមេប្រយោគ នៃមណ្ឌលនីមួយៗ ជាអ្នកទទួលខុសត្រូវរួមចំពោះមុខក្រសួងក្នុងដំណើរការប្រព្រឹត្តិទៅនៃការប្រលងទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេសនៃមណ្ឌលប្រលង ។

ប្រការ ១៦: ប្រធានគណៈមេប្រយោគ ត្រូវសហការ ឬ ផ្ញើអន្តរាគមន៍ដល់អាជ្ញាធរមានសមត្ថកិច្ចនានា ស្ថិតក្នុង ខេត្ត–ក្រុង នៃមណ្ឌលប្រលងក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

ប្រការ ១៧: មណ្ឌល ឬអនុមណ្ឌលប្រលងណាមួយ ដែលមិនមានភាពប្រក្រតីតាមលក្ខណការណ៍នៃការប្រលង ប្រធានគណៈមេប្រយោគនៃមណ្ឌលនោះ ត្រូវរាយការណ៍ជាបន្ទាន់មកគណៈមេប្រយោគទូទាំងប្រទេស ដើម្បីដោះស្រាយ ឬ សុំការសំរេចពីក្រសួងអប់រំយុវជន និងកីឡា ។

ប្រការ ១៨: ប្រធានគណៈមេប្រយោគ ត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិកគណៈមេប្រយោគអោយទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន ។

ប្រការ ១៩: ភារកិច្ចរបស់គណៈកម្មការ និងរបស់សមាជិកគណៈកម្មការផ្សេងៗ នឹងមានចែងក្នុងសេចក្តីណែនាំមួយរបស់ក្រសួងអប់រំយុវជន និងកីឡា ។

ប្រការ ២០: នៅពេលប្រលង បេក្ខជនទាំងឡាយ ត្រូវមកប្រលងអោយទាន់ពេលកំណត់ ។ ការ

មកប្រលងយឺតយ៉ាវលើសពី ១៥ នាទីមិនអនុញ្ញាតអោយចូលប្រលងឡើយ ។ នៅពេលមកប្រលង បេក្ខជនត្រូវមានលិខិតសំគាល់ខ្លួន ដោយមានបិទរូបថត និង មានការបញ្ជាក់ច្បាស់លាស់ ។ បេក្ខជនដែលគ្មានលិខិតសំគាល់ខ្លួនមិនអនុញ្ញាតអោយចូលប្រលងឡើយ ។

ប្រការ ២១: ហាមមិនអោយមានការប្រលងជំនួសគ្នាឡើយ ។

ប្រការ២២: មិនអនុញ្ញាតអោយបេក្ខជនទាំងឡាយយកឯកសារនានាជាប់នឹងខ្លួនចូលក្នុងបន្ទប់ប្រលងជាដាច់ខាត ។

ប្រការ២៣: បេក្ខជនទាំងឡាយត្រូវអង្គុយតាមលេខតុរបស់ខ្លួននៅគ្រប់វិញ្ញាសា ។

ប្រការ២៤: បេក្ខជនទាំងឡាយត្រូវធ្វើវិញ្ញាសាលើក្រដាសប្រលង ដែលអនុរក្សចែកអោយ ។ បេក្ខជន មិនត្រូវធ្វើសញ្ញាអ្វីលើក្រដាសប្រលង ដែលនាំអោយស្គាល់ថាជាសន្លឹកកិច្ចការរបស់សាម៉ីខ្លួនជាដាច់ខាត ។ សន្លឹកកិច្ចការប្រលងណាដែលមានសញ្ញាសំគាល់ត្រូវបានពិន្ទុសូន្យ ។

ប្រការ២៥: នៅពេលធ្វើវិញ្ញាសាប្រលង មិនអនុញ្ញាតអោយបក្ខជនលួចចំលង ឬមានបំណងលួចចំលងជាដាច់ខាត ។ កំហុសនៃការលួចចំលង ឬ បំណងលួចចំលងនឹងមានចែងក្នុងអត្ថបទមួយ ។

ប្រការ២៦: វិញ្ញាសា និងថេរវេលានៃការប្រលងសញ្ញាប័ត្រមធ្យមសិក្សាភូមិ ១ លើកទី ១ និង លើក ទី ២ ត្រូវកំណត់ដូចតទៅ :

១–តែងសេចក្តី រយៈពេល ២ ម៉ោង

២–ជីវវិទ្យា–ភូមិវិទ្យា រយៈពេល ២ ម៉ោង

៣–រូបវិទ្យា–គីមី រយៈពេល ២ ម៉ោង

៤–សីលធម៌ ពលរដ្ឋវិជ្ជា រយៈពេល ១ ម៉ោង និង ៣០ នាទី

៥–សរសេរតាមអាន និងសំណួរ ៤៥ នាទីបន្ទាប់ពីសរសេរតាមអាន

៦–គណិតវិទ្យា រយៈពេល ២ ម៉ោង

ថេរវេលានៃការប្រព្រឹត្តទៅនៃវិញ្ញាសាត្រូវគិតចាប់ពីពេលចំលងប្រធានវិញ្ញាសាចប់។

ប្រការ២៧: ប្រធានវិញ្ញាសាប្រល... ត្រូវយកតាមកម្មវិធីសិក្សាថ្នាក់ទី ៨ នៃមធ្យមសិក្សាភូមិ ១ ។ វិញ្ញាសាទាំងអស់ជាវិញ្ញាសាសរសេរ ។

ប្រការ២៨: ប្រធានវិញ្ញាសាទាំងឡាយត្រូវស្នើដោយគ្រូបង្រៀនថ្នាក់ទី ៨ និងជ្រើសរើសកែលំអ ឬ តាក់តែងដោយមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ។

ប្រការ២៩: ប្រធានវិញ្ញាសាទាំងឡាយដែលជ្រើសរើសរួចហើយ ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ហើយត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច ដែលមានមណ្ឌលប្រលងអោយរក្សាទុក ៤៨ ម៉ោង មុន ពេលចាប់ផ្តើមប្រលង ។

ប្រការ៣០: អាជ្ញាធរមានសមត្ថកិច្ច ដែលរក្សាទុកប្រធានវិញ្ញាសានេះ ត្រូវប្រគល់អោយប្រធានគណៈមេប្រយោគចំពោះមុខសមាជិកនៅថ្ងៃចាប់ផ្តើមការប្រលងមួយម៉ោងមុនពេលបើកសម័យប្រលង ។

ប្រការ៣១: ការប្រគល់អោយ និងការទទួលយកនូវប្រធានវិញ្ញាសាប្រលង ត្រូវមានការទទួលខុសត្រូវទាំងសងខាង ដោយមានកំណត់ហេតុជាផ្លូវការ ។

ប្រការ៣២: ចំនួនប្រធានវិញ្ញាសានីមួយៗ ត្រូវមានចំនួនស្មើនឹងចំនួនបន្ទប់ប្រលង បើខ្វះត្រូវចំលង បន្ថែមបង្គាប់ភ្លាម ។

ប្រការ៣៣: វិញ្ញាសានីមួយៗ ត្រូវអោយពិន្ទុពីសូន្យដល់ដប់ ហើយពុំមានមេគុណទេ ។ នឹងត្រូវបានសូន្យ ចំពោះបេក្ខជនអវត្តមាន និង បេក្ខជនដែលមិនបានប្រគល់វិញ្ញាសាជូនដល់គណៈមេប្រយោគ។

ប្រការ៣៤: វិញ្ញាសាសរសេរនីមួយៗ ត្រូវកែដោយសមាជិកកំនែពីរនាក់ជាដាច់ខាត តាមតារាងអត្រាដែលគណៈមេប្រយោគសំរេច ។

ប្រការ៣៥: វិញ្ញាសាសរសេរតាមអាន ត្រូវគិតជាពីរផ្នែកគឺ ពិន្ទុសរសេរតាមអាន ០៥ ពិន្ទុ ពិន្ទុសំនួរ ០៥ ពិន្ទុ ។ សំនួរសរសេរតាមអាន ត្រូវអានអោយបេក្ខជនសរសេរ គឺមិនត្រូវសរសេរលើក្តារខៀនឡើយ។

ប្រការ៣៦: «ពាក្យ » សរសេរខុសនៅក្នុងសរសេរតាមអាន ត្រូវយកកំហុសតាមតារាងអត្រាកំនែដែលគណៈមេប្រយោគបានសំរេច ។

ប្រការ៣៧: នឹងត្រូវប្រកាសថាប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត១ បេក្ខជនទាំងឡាយដែលបានពិន្ទុសរុបចំនួន ៣០ «សាមសិប» ឡើងទៅដោយឥតមានពិន្ទុសូន្យ ចំពោះវិញ្ញាសាណាមួយឡើយ «ជីវវិទ្យា ជាវិញ្ញាសាមួយ ហើយភូមិវិទ្យាគីមី ក៏ជាវិញ្ញាសាមួយដែរ » និងដោយឥតមានពិន្ទុស្មើ នឹងមួយ ឬ តិចជាងមួយចំពោះវិញ្ញាសាគណិត

វិទ្យា ឬ វិញ្ញាសាតែងសេចក្តី ។

– ក្នុងករណីចាំបាច់គណៈមេប្រយោគអាចធ្វើសំរង់អោយជាប់បន្ថែមក្រោមការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡា ទៅតាមភាពជាក់ស្តែង និង តាមសំណើរបស់គណៈមេប្រយោគ ហើយត្រូវមានកំណត់ ហេតុបញ្ជាក់ច្បាស់លាស់ពីសំរង់បន្ថែម ។ ចំពោះបេក្ខជនស្វ័យរិនឥតមានធ្វើសំរង់អោយជាប់បន្ថែមឡើយ ។

ប្រការ៣៨: គណៈមេប្រយោគមណ្ឌលប្រលងនីមួយៗ ត្រូវប្រជុំពិភាក្សារួម ដើម្បីសំរេចលទ្ធផលនៃការប្រលង ។ កំណត់ហេតុបញ្ជីចាំបាច់នានា ត្រូវបញ្ជូនទៅក្រសួងអប់រំយុវជន និង កីឡា ជាពីរច្បាប់ ដើម្បីសុំសេចក្តីយល់ព្រម ។

ប្រការ៣៩: និទ្ទេសដែលត្រូវកំណត់មានដូចតទៅ :

–ចាប់ពីពិន្ទុសរុប ៣០,០០ ទៅពិន្ទុសរុប ៣៨,៧៥ : និទ្ទេសមធ្យម
–ចាប់ពីពិន្ទុសរុប ៣៩,០០ ទៅពិន្ទុសរុប ៤៧,៧៥ : និទ្ទេសល្អបង្គួរ
–ចាប់ពីពិន្ទុសរុប ៤៨,០០ ឡើងទៅ : និទ្ទេសល្អ

ប្រការ៤០: នឹងត្រូវបានប្រកាសថា ជាប់ជាបេក្ខជនប្រលងលើកទី២ បេក្ខជនទាំងឡាយណាដែលមិនបានប្រកាសថាប្រលងជាប់សញ្ញាប័ត្រលើកទី១ ហើយបានពិន្ទុចាប់ពី ១៨ ឡើងទៅ ដោយមិនគិត ពិន្ទុសូន្យចំពោះមុខវិជ្ជាណាមួយ ។

ប្រការ៤១: ការប្រកាសថាជាប់ជាបេក្ខជនប្រលងលើកទី ២ នឹងត្រូវប្រកាសក្រោយពីប្រកាសលទ្ធផលប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ១ លើកទី ១ បន្ទាប់ពីមានការយល់ព្រមពីមន្ទីរអប់រំយុវជន និងកីឡា ខេត្ត–ក្រុង ។

ប្រការ៤២: បទបញ្ញត្តិស្តីពីការប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត១ ពីមុនៗ ទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៤៣: ប្រធានមន្ទីរ និង ប្រធាននាយកដ្ឋានចំណោះខ្ទង់ទៅ និងមន្ត្រីគយសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវចាត់ការតាមភារកិច្ចរៀងៗខ្លួន ដើម្បីអោយបានសំរេច និងអោយមានប្រសិទ្ធភាពតាមប្រកាសនេះ ។

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

តា សោភាន

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ៤៦៨ រៀល